# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៧-០២-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៧ បំពាក់មេដាយព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ៤៤០ |
| ១៧-០២-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៨ តែងតាំងឯកឧត្តមឱសថការី **លឹម ដារាមាណី** ជាអគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងសុខាភិបាល | ៤៤១ |
| ១៧-០២-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៩ តែងតាំងឯកឧត្តម **ទី នរិទ្ធ** ជាប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា | ៤៤២ |
| ១៩-២-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០២០១/០៤០ តែងតាំងឯកឧត្តម **ថ្វាំ សាយហេង** ជាឧបការីសម្តេចក្រុមព្រះនរោត្តម **រណឫទ្ធិ** ប្រធានរដ្ឋសភា | ៤៤៣ |
| ២០-២-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០២០១/០៤១ តម្លើងឋានៈព្រះអង្គម្ចាស់ក្សត្រិយ៍នរោត្តម **វត្តនាទេវី** ជាឧបការីប្រធានរដ្ឋសភា | ៤៤៤ |
| ២០-២-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០២០១/០៤២ តែងតាំងលោកជំទាវ **ជុន ចំណាន** ជាឧបការីប្រធានរដ្ឋសភា | ៤៤៥ |
| ២០-២-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០២០១/០៤៣ តែងតាំងឯកឧត្តម **ពេជ្រ សុខុម** ជាឧបការីប្រធានរដ្ឋសភា | ៤៤៦ |
| ២២-២-២០០១ | -ព្រះរាជក្រឹត្យ ជស/រកត/០២០១/០១ តែងតាំងឯកឧត្តម **ជា សៀន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា | ៤៤៧ |


## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ១៦-០២-២០០១ | -អនុក្រឹត្យលេខ ១៩ អនក្រ.បក ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ ខេត្តបន្ទាយមានជ័យ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ | ៤៤៩ |

| | | |
|---|---|---|
| ១៦-០២-២០០១ | -អនុក្រឹត្យលេខ ២០ អនក្រ.បក ស្តីពីការលុបនាទីឡូត៍នេសាទ និងរក្សាទុកដែននេសាទក្នុងនាទីឡូត៍នេសាទ ខេត្តក្រចេះ ទុកសំរាប់ប្រជា ពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ | ៤៥១ |
| ១៦-០២-២០០១ | -អនុក្រឹត្យលេខ ២១ អនក្រ.បក ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ ខេត្តកំពង់ចាម ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ | ៤៥៤ |
| ១៦-០២-២០០១ | -អនុក្រឹត្យលេខ ២២ អនក្រ.បក ស្តីពីការលុបដែននេសាទក្នុងនាទីឡូត៍នេសាទ និងគន្លងដាយត្រីរាជធានីភ្នំពេញ ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទជាលក្ខណៈគ្រួសារ | ៤៥៧ |
| ១៩-០២-២០០១ | -អនុក្រឹត្យលេខ ២៣ អនក្រ.បក ស្តីពីការលុបដែននេសាទក្នុងឡូត៍នេសាទ ខេត្តក្រចេះ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ | ៤៦០ |
| ១៩-០២-២០០១ | -អនុក្រឹត្យលេខ ២៤ អនក្រ.បក ស្តីពីការលុបថ្លៃឈ្នួលដែននេសាទ លើឧបករណ៍នេសាទសិប្បកម្មទឹកសាប | ៤៦៣ |
| ២០-០២-២០០១ | -អនុក្រឹត្យលេខ ២៥ អនក្រ.បក ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ | ៤៦៤ |
| ១៦-០២-២០០១ | -អនុក្រឹត្យលេខ ៧២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៦៦ |
| ១៦-០២-២០០១ | -អនុក្រឹត្យលេខ ៧៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៦៨ |
| ១៦-០២-២០០១ | -អនុក្រឹត្យលេខ ៧៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៦៩ |
| ១៦-០២-២០០១ | -អនុក្រឹត្យលេខ ៧៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៧១ |
| ១៩-០២-២០០១ | -អនុក្រឹត្យលេខ ៧៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៤៧២ |
| ១៩-០២-២០០១ | -អនុក្រឹត្យលេខ ៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៧៣ |
| [illegible]-០២-២០០១ | -អនុក្រឹត្យលេខ ៧៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ៤៧៤ |
| [illegible]០០១ | -អនុក្រឹត្យលេខ ៧៩ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា | ៤៧៥ |
| [illegible]០០១ | -អនុក្រឹត្យលេខ ៨០ អនក្រ.តត ស្តីពីការជូនមេដាយការងារថ្នាក់មាស | ៤៧៧ |
| ២២-០២-២០០១ | -អនុក្រឹត្យលេខ ៨១ អនក្រ.តត ស្តីពីការជូនមេដាយការងារថ្នាក់ប្រាក់ | ៤៨១ |
| ២២-០២-២០០១ | -អនុក្រឹត្យលេខ ៨២ អនក្រ.តត ស្តីពីការជូនមេដាយការងារថ្នាក់សំរិទ្ធ | ៤៨៧ |

## III-ការិយាល័យក្រសួង

### ១.ធនាគារជាតិនៃកម្ពុជា

#### ប្រកាស


| | | |
|---|---|---|
| ២២-០២-២០០១ | -ប្រកាសលេខ ធ៧-០១-៣៥ ប្រក. ស្តីពីការតែងតាំងអភិបាលណ្តោះអាសន្ន និង អ្នកជំរះបញ្ជីធនាគារពាណិជ្ជកម្ម និងកសិកម្មនៃកម្ពុជាចំកាត់ | ៤៩៥ |
| ២២-០២-២០០១ | -ប្រកាសលេខ ធ៧-០១-៣៦ ប្រក. ស្តីពីការតែងតាំងអភិបាលណ្តោះអាសន្ន និង អ្នកជំរះបញ្ជីធនាគារបូរីភ្នំពេញ ចំកាត់ | ៤៩៧ |
| ២២-០២-២០០១ | -ប្រកាសលេខ ធ៧-០១-៣៧ ប្រក. ស្តីពីការតែងតាំងអភិបាលណ្តោះអាសន្ន និង អ្នកជំរះបញ្ជីធនាគារសន្តិភាពពាណិជ្ជ ចំកាត់ | ៤៩៩ |
| ២២-០២-២០០១ | -ប្រកាសលេខ ធ៧-០១-៣៨ ប្រក. ស្តីពីការតែងតាំងអភិបាលណ្តោះអាសន្ន និង អ្នកជំរះបញ្ជីធនាគាររីជណៃស៊ិរណ ចំកាត់ | ៥០១ |
| ២២-០២-២០០១ | -ប្រកាសលេខ ធ៧-០១-៣៩ ប្រក. ស្តីពីការតែងតាំងអភិបាលណ្តោះអាសន្ន និង អ្នកជំរះបញ្ជីធនាគារអន្តរជាតិ ចំកាត់ | ៥០៤ |
| ២២-០២-២០០១ | -ប្រកាសលេខ ធ៧-០១-៤០ ប្រក. ស្តីពីការតែងតាំងអភិបាលណ្តោះអាសន្ន និង អ្នកជំរះបញ្ជីធនាគារកសិករកម្ពុជា ចំកាត់ | ៥០៦ |


### ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

#### ១.ប្រកាស


| | | |
|---|---|---|
| ១៩-០២-២០០១ | -ប្រកាសលេខ ១២៦ អយក.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ | ៥០៨ |


#### ២.សារាចរណែនាំ


| | | |
|---|---|---|
| ១៩-០២-២០០១ | -សារាចរណែនាំលេខ ០១ អយក.សរណន ស្តីពីការរៀបចំប្រឡងសញ្ញាប័ត្រចំណេះទូទៅ និង បំពេញវិជ្ជា | ៥១៦ |

១៩-០២-២០០១ -សារាចរណែនាំលេខ ០២ អយក.សរណន ស្តីពីការប្រឡងបញ្ចប់ភូមិសិក្សា ផ្នែកចំណេះទូទៅបំពេញវិជ្ជាសាធារណៈ និង ឯកជន ៥២៥


## ៣. ទីស្តីការក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ

### ប្រកាស


២១-០២-២០០១ -ប្រកាសលេខ ០៨៤ ប្រ.កសក.បុ ស្តីពីការបង្កើតការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ៥៣១

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

## ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៧

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានបំពាក់មេដាយ ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម **ចាម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលបានយកអស់កម្លាំងកាយចិត្ត ខិតខំបំពេញភារកិច្ច ហើយទទួលបានស្នាដៃល្អក្នុងការអនុវត្តន៍នូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល លើវិស័យពាណិជ្ជកម្ម ។

**មាត្រា ២.-**

នាយករដ្ឋមន្ត្រីនៃព្រះរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០០១

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

***

**ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៨**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា ១.-**

តែងតាំងឯកឧត្តមឱសថការី **លឹម ដារាមាណី** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងសុខាភិបាល ។

**មាត្រា ២.-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០១

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

***

**ព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៩**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១

## ប្រកាសបង្គាប់

**មាត្រា ១.-**

តែងតាំងឯកឧត្តម **ឆី នរិន្ទ** ជាប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជាមានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២.-**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ មានលេខានុការមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

## ព្រះរាជក្រឹត្យ នស/រកត/០២០១/០៤០

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ០៨៩ រស ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១
- យោងតាមសំណូមពរការងារចាំបាច់

## ប្រកាសបង្គាប់

**មាត្រា ១.-**

តែងតាំងឯកឧត្តម **ទ្រាំ សាយហេង** ជាឧបការីសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២.-**

ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបាន សំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០០១

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

***

## ព្រះរាជក្រឹត្យ នស/រកត/០២០១/០៤១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ១៣.រស ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០១

- យោងតាមសំណូមពរការងារចាំបាច់

**ត្រាស់បង្គាប់**

**មាត្រា ១.-**

ពង្រើងឋានៈព្រះអង្គម្ចាស់ក្សត្រិយ៍ **នរោត្តម តេជរង្សី** ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២.-**

ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

**ព្រះរាជក្រឹត្យ នស/រកត/០២០១/០៤២**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ១៤.រស ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០១

- យោងតាមសំណូមពរការងារចាំបាច់

**ត្រាស់បង្គាប់**

**មាត្រា ១.-**

តែងតាំងលោកជំទាវ ជុំ ចំរើន ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២.-**

ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០១

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

※※※

**ព្រះរាជក្រឹត្យ នស/រកត/០២០១/០៤៣**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និកោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

❊❊❊

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ១៥.រស ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០១

- យោងតាមសំណូមពរការងារចាំបាច់

**ត្រាស់បង្គាប់**

**មាត្រា ១.-**

តែងតាំងឯកឧត្តម **ពៅ សុខុម** ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២.-**

ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

**ព្រះរាជក្រឹត្យ ជស/រកត/០២០១/០១**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់ឱ្យប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និង

មាត្រាទាំងឡាយនៃ ជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបាន អនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី ១ និងអនុប្រធានទី ២ នៃព្រឹទ្ធសភា

- យោងតាមសំណូមពរចាំបាច់នៃការងារ

**ត្រាស់បង្គាប់**

**មាត្រា ១.-**

តែងតាំងឯកឧត្តម **ជា សឿន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មមូលបន្ទុកការងារសហជីព វិនិយោគ និងបរិស្ថាន មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២.-**

ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០១

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

បាត្តលេខា

**ជា ស៊ីម**

***

## II- រាជរដ្ឋាភិបាល

### អនុក្រឹត្យ

### អនុក្រឹត្យលេខ ១៩ អនក្រ.បក

### ស្តីពីការលុបនាទីឡូត៍នេសាទ

### និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ

### ខេត្តបន្ទាយមានជ័យ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣.ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សំរេច

**មាត្រា ១.-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទបំរុងទុកនៅទឹកសាប ក្នុងខេត្តបន្ទាយមានជ័យ ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទលេខ៣ និងលេខ៤ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅដោយរក្សាទុកអន្លង់ត្រីមេពូជដូចខាងក្រោម ៖
    - ឡូត៍នេសាទលេខ ៣ រក្សាទុកអន្លង់ត្រីមេពូជមួយកន្លែងត្រង់ចំនុចវត្តតាសល់ ក្នុងឃុំគោកបាឡាំង ដែលមានចំងាយសងខាងវត្តមួយគីឡូម៉ែត្រផ្នែកខាងលើ និងមួយគីឡូម៉ែត្រផ្នែកខាងក្រោម ដែលមានផ្ទៃក្រឡាសរុប ៩ ហិកតា ។
    - ឡូត៍នេសាទលេខ ៤ រក្សាទុកអន្លង់ត្រីមេពូជនៅត្រង់ចំនុចវត្តភ្លៀត ក្នុងភូមិភ្លៀត និងអន្លង់វត្តកោះ ។ អន្លង់ទាំងពីរនេះត្រូវរក្សាការពារ ចាប់ពីមាត់អន្លង់តាមបណ្តោយដងស្ទឹងទៅខាងលើ ២០០ម និងពីមាត់អន្លង់ទៅខាងក្រោម ២០០ម ដែលមានផ្ទៃក្រឡាសរុប ៤ ហិកតា ។
- កាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែននេសាទក្នុងខេត្តបន្ទាយមានជ័យ និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តបន្ទាយមានជ័យ ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា (ហិកតា)

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ១២.៩១៦ | ១១.៧៣៨ | ១.១៧៨ | ៩០.៨៨ | |
| ២ | ៥.៣៤៣ | ១២៣ | ៥.២២០ | ២.៣០ | |
| ៣ | ៧.៤៧០ | ៧.៤៦១ | ៩ | ៩៩.៨៧ | លុបចេញ រក្សាទុក ៩ ហ.ត |
| ៤ | ៧.០២៧ | ៧.០២៣ | ៤ | ៩៩.៩៤ | លុបចេញ រក្សាទុក ៤ ហ.ត |
| **សរុប ៤** | ៣២.៧៥៦ | ២៦.៣៤៥ | ៦.៤១១ | ៨០.៤២ | |

មាត្រា ២.-

ដែននេសាទដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនឱ្យជនណាមួយហ៊ុងហែងយកទៅលក់ ឬជួលឱ្យឯកជនធ្វើអាជីវកម្មផ្ទាល់មុខឡើយ ។

មាត្រា ៣ .-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

មាត្រា ៤ .-

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

※※※

**អនុក្រឹត្យលេខ ២០ អនក្រ.បក**

**ស្តីពី**

**ការលុបនាទីឡូត៍នេសាទ និងរក្សាទុកដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តក្រចេះ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ**

❀❀❀

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣.ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**មាត្រា ១.-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទបំរុងនៅទឹកសាប ក្នុងខេត្តក្រចេះ ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទបឹងព្រែកទាំងអស់ក្នុងខេត្តក្រចេះ គឺឡូត៍បឹងព្រែកលេខ ៣. ៤. ៥. ៦. ៧. ៩. ១០ និងលេខ ១១ ព្រមទាំងឡូត៍ឆ្នេរខ្សាច់លេខ ១. ៥. ៧. ៩ និង លេខ ១០ ចាប់ពីរដូវនេសាទឆ្នាំ ២០០១-២០០២ តទៅ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តក្រចេះ ដែលត្រូវលុប និងរក្សាទុក**

ឯកតា (ហិកតា)

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ៣ | ៣២៦ | ៣២៦ | ០ | ១០០ | លុបចេញ |

| | | | | | |
|---|---|---|---|---|---|
| ៤ | ១៥០ | ១៥០ | ០ | ១០០ | លុបចេញ |
| ៥ | ៣១៦ | ៣១៦ | ០ | ១០០ | លុបចេញ |
| ៦ | ១.៦៧៥ | ១.៦៧៥ | ០ | ១០០ | លុបចេញ |
| ៧ | ៥៦៤ | ៥៦៤ | ០ | ១០០ | លុបចេញ |
| ៩ | ១៩៤ | ១៩៤ | ០ | ១០០ | លុបចេញ |
| ១០ | ៣.៤៦៣ | ៣.៤៦៣ | ០ | ១០០ | លុបចេញ |
| ១១ | ១.២៨៦ | ១.២៨៦ | ០ | ១០០ | លុបចេញ |
| **សរុប ក ៨** | **៧.៩៧៤** | **៧.៩៧៤** | ០ | ១០០ | |
| ឆ្នេរខ្សាច់ | | | | | |
| ១ | ៦៨ | ៦៨ | ០ | ១០០ | លុបចេញ |
| ២ | ១៤៦ | ០ | ១៤៦ | ០ | រក្សាទុក |
| ៥ | ៣៨ | ៣៨ | ០ | ១០០ | លុបចេញ |
| ៦ | ១៧៥ | ០ | ១៧៥ | ០ | រក្សាទុក |
| ៧ | ១៥៨ | ១៥៨ | ០ | ១០០ | លុបចេញ |
| ៩ | ៥១ | ៥១ | ០ | ១០០ | លុបចេញ |
| ១០ | ១១៥ | ១១៥ | ០ | ១០០ | លុបចេញ |
| **សរុប ខ ៧** | **៧៥១** | **៤៣០** | **៣២១** | **៥៧,២៥** | |
| **សរុប ក ខ ១៥** | **៨.៧២៥** | **៨.៤០៤** | **៣២១** | **៩៦,៣២** | |

**មាត្រា ២.-**

ដែននេសាទដែលបានលុបចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនឱ្យជនណាមួយហ៊ុងហែងយកទៅលក់ ឬជួលឱ្យឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុបចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា ៤.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

※※※

**អនុក្រឹត្យលេខ ២១ អនក្រ.បក**

**ស្តីពី**

**ការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ ខេត្តកំពង់ចាម ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញក្រឹត្យច្បាប់លេខ ៣៣.ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**មាត្រា ១.-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទបំរុងនៅទឹកសាប ក្នុងខេត្តកំពង់ចាម ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទលេខ ៤ ៦ ៧ ១១ក និងលេខ ១១គ ព្រះទាំងឡូត៍ឆ្នេរខ្សាច់លេខ ១. ៣. ៦. ៨. ៩. ១០. ១៣. ១៧. ១៨. ១៩. ២០ និងលេខ ២១ ចាប់ពីរដូវនេសាទឆ្នាំ ២០០០-២០០១ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែននេសាទក្នុងខេត្តកំពង់ចាម និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មី ចាប់ពីពេលនេះតទៅ ។ ចំពោះឡូត៍នេសាទលេខ ១០ ដែលត្រូវកាត់ ៦.៩៥៦ ហិកតា ចេញពីនាទីឡូត៍នេសាទ ក្នុងនោះរក្សាទុកអន្លង់ត្រីមេពូជ ចាប់ពីស្ពានស្ទឹងគរតី រហូតដល់បឹងជីធាងដែលមានផ្ទៃក្រឡា ១៤២ ហិកតា ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តកំពង់ចាម ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា ( ហិកតា)

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ៣.៤៥០ | ២.៤៣៦ | ១.០១៤ | ៧០.៦០ | |
| ២ | ១០.៩៩២ | ៦.៧៥៣ | ៤.២៣៩ | ៦១.៤៣ | |

| | | | | | |
|---|---|---|---|---|---|
| ៣ | ៣.២៨៤ | ១.៨៥៩ | ១.៤២៥ | ៥៦.៦០ | |
| ៤ | ២.២៨៤ | ២.២៨៤ | 0 | ១០០ | លុបចេញ |
| ៥ | ៤.២០៧ | ២.៨១០ | ១.៣៩៧ | ៦៦.៧៩ | |
| ៦ | ៣.៦៧៤ | ៣.៦៧៤ | 0 | ១០០ | លុបចេញ |
| ៧ | ៣.៨៩៣ | ៣.៨៩៣ | 0 | ១០០ | លុបចេញ |
| ៨ | ៣.៣៣៣ | ១.៧៨៩ | ១.៥៤៤ | ៣៥.៦៧ | |
| ៩ | ៧.៨៣៥ | ៤.៨០១ | ៣.០៣៤ | ៦១.២៧ | |
| ១០ | ១៨.៤៣៤ | ៦.៩៥៦ | ១១.៤៧៨ | ៣៧.៧៣ | រក្សាទុក ១៤២ប.ព |
| ១១ក | ២.១៩៤ | ២.១៩៤ | 0 | ១០០ | លុបចេញ |
| ១១គ | ៥៦២ | ៥៦២ | 0 | ១០០ | លុបចេញ |
| **សរុប ក ១២** | ៦៤.១៤២ | ៤០.០១១ | ២៤.១៣១ | ៦២.៣៨ | |
| ឡូត៍ឆ្នេរខ្សាច់ | | | | | |
| ១ | ២៨ | ២៨ | 0 | ១០០ | លុបចេញ |
| ៣ | ៥៦ | ៥៦ | 0 | ១០០ | លុបចេញ |
| ៦ | ៤២ | ៤២ | 0 | ១០០ | លុបចេញ |
| ៨ | ១៣១ | ១៣១ | 0 | ១០០ | លុបចេញ |
| ៩ | ២០ | ២០ | 0 | ១០០ | លុបចេញ |
| ១០ | ៣៧ | ៣៧ | 0 | ១០០ | លុបចេញ |
| ១៣ | ៥៩ | ៥៩ | 0 | ១០០ | លុបចេញ |
| ១៧ | ៨៣ | ៨៣ | 0 | ១០០ | លុបចេញ |
| ១៨ | ១១២ | ១១២ | 0 | ១០០ | លុបចេញ |
| ១៩ | ៨៣ | ៨៣ | 0 | ១០០ | លុបចេញ |
| ២០ | ១០២ | ១០២ | 0 | ១០០ | លុបចេញ |
| ២១ | ១១០ | ១១០ | 0 | ១០០ | លុបចេញ |
| **សរុប ខ ១២** | **៨៦៣** | **៨៦៣** | **0** | **១០០** | |
| **សរុប កខ ២៤** | **៦៥.០០៥** | **៤០.៨៧៤** | **២៤.១៣១** | **៦២.៨៨** | |

**មាត្រា ២.-**

ដែននេសាទដែលបានលុបចេញ និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនឱ្យជនណាមួយហួងហែងយកទៅលក់ ឬជួលឱ្យឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

※※※

**អនុក្រឹត្យលេខ ២២ អនក្រ.បក**

**ស្តីពី**

**ការលុបដែននេសាទ ក្នុងនាទីឡូត៍នេសាទ លេខគន្លងដាយត្រី**

**រាជធានីភ្នំពេញ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ**

※※※

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣.ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទបំរុងទុកនៅទីកសាប ក្នុងរាជធានីភ្នំពេញ ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទ លេខ១ និងគន្លងដាយ ១B, ១C និង ១D ចាប់ពីរដូវនេសាទឆ្នាំ ២០០១-២០០២ តទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទ និងគន្លងដាយត្រីក្នុងរាជធានីភ្នំពេញ ដែលត្រូវលុប**

ឯកតា ( ហិកតា)

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ៣.៤៧៥ | ៣.៤៧៥ | ០ | ១០០ | លុបចេញ |

| | | | | | |
|---|---|---|---|---|---|
| គន្លងដាយត្រី | | | | | |
| ១B | | | | | លុបចេញ |
| ១C | | | | | លុបចេញ |
| ១D | | | | | លុបចេញ |
| **សរុប ៤** | **៣.៤៧៥** | **៣.៤៧៥** | ០ | ១០០ | |

**មាត្រា ២.-**

ដែននេសាទក្នុងនាទីឡូត៍នេសាទ និងគន្លងដាយត្រីដែលបានលុប ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនឱ្យជនណាមួយហួងហែងយកទៅលក់ ឬជូលឱ្យឯកជនធ្វើអាជីវកម្មផ្ដាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុបចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

✻✻✻

# អនុក្រឹត្យលេខ ២៣ អនក្រ.បក
## ស្តីពី
## ការលុបដែននេសាទក្នុងនាទីឡូត៍នេសាទ ខេត្តក្រចេះ
## ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣.ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

### មាត្រា ១.-

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទបំរុងទុកនៅទឹកសាប ក្នុងខេត្តក្រចេះ ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទបឹងព្រែកទាំងអស់ក្នុងខេត្តក្រចេះ គឺឡូត៍បឹងព្រែកលេខ ៣. ៤. ៥. ៦. ៧. ៩. ១០ និងលេខ ១១ ព្រមទាំងឡូត៍ឆ្នេរខ្សាច់លេខ ១. ២. ៥. ៦. ៧. ៩. និងលេខ ១០ ចាប់ពីរដូវនេសាទឆ្នាំ ២០០១-២០០២ តទៅ ។

## តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តក្រចេះ ដែលត្រូវលុប

ឯកតា ( ហិកតា)

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ៣ | ៣២៦ | ៣២៦ | 0 | ១០០ | លុបចេញ |
| ៤ | ១៥០ | ១៥០ | 0 | ១០០ | លុបចេញ |
| ៥ | ៣១៦ | ៣១៦ | 0 | ១០០ | លុបចេញ |
| ៦ | ១.៦៧៥ | ១.៦៧៥ | 0 | ១០០ | លុបចេញ |
| ៧ | ៥៦៤ | ៥៦៤ | 0 | ១០០ | លុបចេញ |
| ៩ | ១៩៤ | ១៩៤ | 0 | ១០០ | លុបចេញ |
| ១០ | ៣.៤៦៣ | ៣.៤៦៣ | 0 | ១០០ | លុបចេញ |
| ១១ | ១.២៨៦ | ១.២៨៦ | 0 | ១០០ | លុបចេញ |
| **សរុប ក ៨** | **៧.៩៧៤** | **៧.៩៧៤** | 0 | ១០០ | |
| ឆ្នេរខ្សាច់ | | | | | |
| ១ | ៦៨ | ៦៨ | 0 | ១០០ | លុបចេញ |
| ២ | ១៤៦ | ១៤៦ | 0 | ១០០ | លុបចេញ |
| ៥ | ៣៨ | ៣៨ | 0 | ១០០ | លុបចេញ |
| ៦ | ១៧៥ | ១៧៥ | 0 | ១០០ | លុបចេញ |
| ៧ | ១៥៨ | ១៥៨ | 0 | ១០០ | លុបចេញ |
| ៩ | ៥១ | ៥១ | 0 | ១០០ | លុបចេញ |

| | | | | | |
|---|---|---|---|---|---|
| ១០ | ១១៥ | ១១៥ | ០ | ១០០ | លុបចេញ |
| សរុប ខ ៧ | ៧៥១ | ៧៥១ | ០ | ១០០ | |
| សរុប ក ខ ១៥ | ៨.៧២៥ | ៨.៧២៥ | ០ | ១០០ | |

**មាត្រា ២.-**

ដែននេសាទដែលបានលុបចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនឱ្យជនណាមួយហ៊ុំហ៊ួងយកទៅលក់ ឬជួលឱ្យឯកជនធ្វើអាជីវកម្មផ្ដាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុបចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

# អនុក្រឹត្យលេខ ២៤ អនក្រ.បក
# ស្ដីពី ការលុបថ្លៃឈ្នួលដែននេសាទ
# លើឧបករណ៍នេសាទសិប្បកម្មទឹកសាប

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣.ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្ដីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ. ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៨៩ ស្ដីពីការជួលដែននេសាទទឹកសាបនិងសមុទ្រអោយធ្វើអាជីវកម្ម
- បានឃើញប្រកាសរបស់ក្រសួងកសិកម្ម ០២៨ កសក. ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៨៧ ស្ដីពីការកំណត់ឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដែននេសាទទឹកសាប និងសមុទ្រ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

មាត្រា ១.-

លុបការយកថ្លៃឈ្នួលដែននេសាទលើឧបករណ៍នេសាទសិប្បកម្មទឹកសាបគ្រប់ប្រភេទ ចាប់ពីពេលនេះតទៅ ។

**មាត្រា ២.-**

ឧបករណ៍នេសាទសិប្បកម្មគ្រប់ប្រភេទ ដែលបានកំណត់ក្នុងប្រកាសរបស់ក្រសួងកសិកម្ម លេខ ០២៨ កសក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៨៧ ស្តីពីការកំណត់ឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដែននេសាទទឹកសាបនិងសមុទ្រ មិនត្រូវបានអនុញ្ញាតឱ្យធ្វើនេសាទនៅក្នុងរដូវបិទនេសាទឡើយ ។

**មាត្រា ៣ .-**

អ្នកនេសាទគ្រប់រូប មិនត្រូវប្រើប្រាស់ឧបករណ៍នេសាទហាមឃាត់ និងប្រព្រឹត្តសកម្មភាពផ្ទុយនឹងច្បាប់ ឬ លិខិតបទដ្ឋាននានាដែលបានកំណត់រួចហើយនោះទេ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

※※※

## អនុក្រឹត្យលេខ ២៥ អនក្រ.បក

## ស្តីពីស្តីពីការបង្កើត

## ស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា

## ប្រចាំសាធារណរដ្ឋកូរ៉េ

❊❊❊

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា ១.-**

បង្កើតស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ ដោយមាននិវេសនដ្ឋាននៅក្រុងសេអ៊ូល ។

**មាត្រា ២.-**

ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ។

**មាត្រា ៣ .-**

សមាសភាពមន្ត្រីការទូតផ្សេងទៀត មន្ត្រីបច្ចេកទេសនិងបុគ្គលិកសេវា នឹងត្រូវកំណត់តាមតំរូវការនៃការងារជាក់ស្ដែង ។

**មាត្រា ៤ .-**

ប្រព័ន្ធហិរញ្ញកិច្ច សំរាប់មន្ត្រីការទូត មន្ត្រីបច្ចេកទេស និងបុគ្គលិកសេវា នៃស្ថានឯកអគ្គ-រាជទូតនេះនឹងស្ថិតនៅក្នុងប្រភេទ "ក" ។

**មាត្រា ៥.-**

អនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ត្រូវចាត់ទុកជាមោឃៈ ។

**មាត្រា ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យលេខ ៧២ អនក្រ.បក**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា ១.-**

ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ប្រគេន និងជូនលោក-លោកស្រី ដែលបានបរិច្ចាគ និងថវិកាផ្ទាល់ខ្លួន ដើម្បីកសាងសំណង់នានា ក្នុងវិស័យអប់រំ ដូចជាសាលាបឋម

សិក្សា ស្ពាយអណ្តែត-តាជោ ស្ពានថ្ម និងបង្គន់អនាម័យ នៅក្នុងឃុំសារិកាកែវ ស្រុកល្វាឯម ដូចមានរាយព្រះនាម និងនាមខាងក្រោម :

**ក-មេដាយមាសស្ថាបនាជាតិ :**

១- លោកស្រី **ឌីនី ហ្វាន់ប្រ៊ូហ្គែន** DINY VANBRUGGEN ប្រធានអង្គការស្ពានកម្ពុជា-ហូឡង់ ថវិកា ២៤.៧២៤ ដុល្លាអាមេរិក

២- លោក **អូលដ៍** OLD សមាជិកអង្គការស្ពានកម្ពុជា-ហូឡង់ ថវិកា ១៥.៣៥០ ដុល្លាអាមេរិក

៣- លោក **រ៉ូឡូហ្វហ្វាន ប្រ៊ុយហ្គែន** ROCLOF VAN BRUGGEN សមាជិកអង្គការស្ពានកម្ពុជា-ហូឡង់ ថវិកា ១០.០០០ ដុល្លារអាមេរិក

៤- ព្រះសង្ឃ-គណៈកម្មការអាចារ្យវត្ត ពុទ្ធបរិស័ទ និងអាជ្ញាធរ ឃុំសារិកាកែវ ថវិកា ១០.៦៨២ ដុល្លាអាមេរិក

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១- លោក **ខួន ផាន** ប្រធានអង្គការស្ពានកម្ពុជា ថវិកា ៥.១០០ ដុល្លារអាមេរិក

២- លោក **លាវ ហុកគី** អនុប្រធានសមាគមខ្មែរសាមគ្គីសង្គ្រោះនៅសហរដ្ឋអាមេរិក ថវិកា ៥.០៥០ ដុល្លារអាមេរិក

៣- លោកតា **សួ នឹម** ប្រធានកិត្តិយសគណៈកម្មការសាងសង់ ឃុំសារិកាកែវ ថវិកា ៥.០០០ ដុល្លារអាមេរិក

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១- សមាគមខ្មែរសាមគ្គីសង្គ្រោះ នៅសហរដ្ឋអាមេរិក ថវិកា ២.៥០០ ដុល្លារអាមេរិក

២- អ្នកស្រី អ៊ុំ នៅ សមាជិកសមាគមសាមគ្គីសង្គ្រោះ នៅសហរដ្ឋអាមេរិក ថវិកា ១.១៥០ ដុល្លារអាមេរិក

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាល ខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យលេខ ៧៣ អនក្រ.គត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

**សម្រេច**

**មាត្រា ១.-**

ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនចំពោះសប្បុរសជន ០២រូប ខ្មែរនៅសហរដ្ឋអាមេរិក ដែលបានជួយកសាងវត្ត ព្រះវិហារ សាលារៀន និងម៉ាស៊ីនភ្លើង ស្ថិតក្នុងវត្តត្រពាំងព្រីង និងវត្តពោធិរុក្ខារាម ឃុំសំឡី ស្រុកកំពង់រោទិ៍ ដូចមានឈ្មោះខាងក្រោម :

១- លោក **សោម តា និង ភរិយា** ថវិកា ១១.០៨៥ ដុល្លាអាមេរិក

២- លោក **ឡុង លីម និង ភរិយា** ថវិកា ១០.៣៤៥ ដុល្លាអាមេរិក

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

※※※

**អនុក្រឹត្យលេខ ៧៤ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

❈❈❈

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា ១.-**

ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជនចំនួន ២០រូប ដែលបានជួយកសាងសំណង់នានា ផ្នែកវិស័យព្រះពុទ្ធសាសនា នៅក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :

**ក.មេដាយមាសស្ថាបនាជាតិ :**

១- ភិក្ខុមនីបញ្ញោ **សួន មីនគង់** នៅសហរដ្ឋអាមេរិក បច្ច័យ ៤៨.៩៥០ ដុល្លារអាមេរិក
២- ឧបាសិកា **មេទូច សុខឡៀង** នៅសហរដ្ឋអាមេរិក ថវិកា ១៦.២០០ ដុល្លារអាមេរិក
៣- ឧបាសក **គង់ សុវណ្ណ** នៅសហរដ្ឋអាមេរិក ថវិកា ១៥.២៤០ ដុល្លារអាមេរិក
៤- ឧបាសក **តាំង ម៉ូចឃុន** នៅរាជធានីភ្នំពេញ ថវិកា ១៥.០០០ ដុល្លារអាមេរិក
៥- ឧបាសិកា **គីម ហួយ** នៅសហរដ្ឋអាមេរិក ថវិកា ១៣.៤២៥ ដុល្លារអាមេរិក
៦- ឧបាសិកា **ង្វៀក ស៊ីវអ៊ីម** នៅសហរដ្ឋអាមេរិក ថវិកា ១៣.២០០ ដុល្លារអាមេរិក
៧- លោក **ឡាយ ឡៀងគ័ង** នៅសហរដ្ឋអាមេរិក ថវិកា ១២.៣៥០ ដុល្លារអាមេរិក
៨ លោក **តឹក ប៊ុនមេងហ័ង** នៅប្រទេសបារាំង ថវិកា ១២.៣០០ ដុល្លារអាមេរិក
៩- ឧបាសក **ទង់ គីត** នៅប្រទេសបារាំង ថវិកា ១០.៥០០ ដុល្លារអាមេរិក
១០- ឧបាសក **អ៊ឹង ឈុនហេង** នៅរាជធានីភ្នំពេញ ថវិកា ១០.៣៥០ ដុល្លារអាមេរិក
១១- ឧបាសក **ឡា ហាំងហួរ** នៅរាជធានីភ្នំពេញ ថវិកា ១០.២៥០ ដុល្លារអាមេរិក

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

១- ឧបាសក **លី ណេង** នៅឃុំព្រះប្រសប់ ថវិកា ៨.០០០ ដុល្លារអាមេរិក
២- ឧបាសក **ជួង សៀងគង់** នៅឃុំព្រះប្រសប់ ថវិកា ៨.០០០ ដុល្លារអាមេរិក
៣- ឧបាសក **ហ៊ុន អួន** នៅឃុំព្រះប្រសប់ ថវិកា ៨.០០០ ដុល្លារអាមេរិក
៤- ឧបាសក **តែ ឡៀសៀ** នៅសហរដ្ឋអាមេរិក ថវិកា ៧.៨០០ ដុល្លារអាមេរិក
៥- ឧបាសក **ឡេង គង់** នៅរាជធានីភ្នំពេញ ថវិកា ៧.៥០០ ដុល្លារអាមេរិក
៦- ឧបាសក **ទៅ ថៃ** នៅឃុំតាឯក ថវិកា ៥.៨៥០ ដុល្លារអាមេរិក
៧- ឧបាសក **សុខ គីលីម** នៅឃុំព្រែកតាមាក់ ថវិកា ៥.១០០ ដុល្លារអាមេរិក

**គ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

១- ឧបាសក **ចាប សម្បត្តិ** នៅឃុំព្រែកតាមាក់ ថវិកា ៣.១៧៨ ដុល្លារអាមេរិក
២- ឧបាសក **ថៃ ស្រេង** នៅឃុំព្រែកតាមាក់ ថវិកា ២.០១១ ដុល្លារអាមេរិក

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

※※※

## អនុក្រឹត្យលេខ ៧៥ អនក្រ.តត

## ស្តីពីការជូនមេដាយស្ហាមនាជាតិ

❊❊❊

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានប្រគល់ **មេដាយមាសស្ហាមនាជាតិ** ជូនសប្បុរសជន ០២រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួនជួយកសាងសាលាបាលីក្នុងវិស័យព្រះពុទ្ធសាសនាចំនួន ០១ខ្នង មាន ០៣បន្ទប់ បណ្តោយ ១៩ម៉ែត្រ ទទឹង ១០ម៉ែត្រ ធ្វើអំពីបេតុងប្រក់ក្បឿង ស្ថិតនៅវត្តអង្គបឹងចក ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :

**ក.មេដាយមាសស្ថាបនាជាតិ :**

-លោកស្រី **លាង ថោងអាំង** ខ្មែរនៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១៨.០០០ ដុល្លារអាមេរិក

**ខ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

-លោក **ហួរ ស៊ុន** ប្រធានគណៈកម្មការសាងសង់វត្តអង្គបឹងចក ថវិកា ចំនួន ៣.០០០ ដុល្លារអាមេរិក

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

※※※

**អនុក្រឹត្យលេខ ៧៦ អនក្រ.តត**

**ស្ដីពីការតែងតាំងមន្ត្រីរាជការ**

❈❈❈

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៩/១៣៨ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការកែសំរួលខ្លឹមសារនៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៩/១៦ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
**ស្តីពីការតែងតាំងអភិបាលបណ្តោះអាសន្ន និងអ្នកជំរះបញ្ជី**

**វិសាលធនាគារអន្តរជាតិ ចំកាត់**

***

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសប្រើច្បាប់ស្តីពីគ្រឹស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- បានឃើញអាជ្ញាប័ណ្ណលេខ ២៣ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៩៣ ដែលចេញឱ្យវិសាលធនាគារអន្តរជាតិ ចំកាត់ តទៅនេះហៅថា "ធនាគារ"
- បានឃើញប្រកាសលេខ ធ ៧០០-១៥៨ ប្រក ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការដកហូតអាជ្ញាប័ណ្ណ និងជំរះបញ្ជីរបស់វិសាលធនាគារអន្តរជាតិ ចំកាត់
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

**សំរេច**

**ប្រការ ១ :**

តែងតាំងលោក Donat Branger ជាអ្នកអភិបាលបណ្តោះអាសន្ន និងជាអ្នកជំរះបញ្ជីវិសាលធនាគារអន្តរជាតិ ចំកាត់ តាមការកំណត់មាត្រាទី ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។

**ប្រការ ២ :**

អ្នកជំរះបញ្ជី មានភារកិច្ច :

- រៀបចំជាបន្ទាន់នូវការវាយតំលៃធនាគារ
- ការពារឱ្យបានជាអតិបរមានូវសាធនភាពរបស់ធនាគារ និងរក្សាសិទ្ធិរបស់អ្នកផ្ញើប្រាក់ និងឥណទាយក ។
- ជំរះបញ្ជីទ្រព្យសកម្ម និងសងបំណុលទាំងអស់របស់ធនាគារ ក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។
- មុននឹងបញ្ចប់ការអភិបាលបណ្ដោះអាសន្ន និងការជំរះបញ្ជី ស្នងការគណនីត្រូវធ្វើលិខិតបញ្ជាក់ថា សាមីធនាគារដែលត្រូវត្រួតពិនិត្យបញ្ជីមិនមានការពាក់ព័ន្ធអ្វីទៅអនាគតទេ ប្រសិនបើថ្ងៃក្រោយមានបញ្ហាអ្វីកើតឡើងសាមីធនាគារជាអ្នកទទួលខុសត្រូវដោយខ្លួនឯង ។
- ផ្ដល់ពត៌មានជាទៀងទាត់មកធនាគារជាតិ នៃកម្ពុជា អំពីដំណើការនៃការងារនឹងផ្ញើមកធនាគារជាតិនូវរបាយការណ៍ (ជាភាសាខ្មែរ និងភាសាអង់គ្លេស) អំពីបញ្ហាដែលទាក់ទងទៅនឹងការវិវត្តន៍ការជំរះបញ្ជី ព្រមទាំងបញ្ជាក់ពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ដូចជា :
  - ឥណទានដែលបានផ្ដល់
  - ប្រាក់បញ្ញើរបស់អតិថិជន
  - ចំណាយផ្សេងៗទាក់ទង និងពន្ធដារ

**ប្រការ ៣ :**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៤ :**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសាភិបាល

ហត្ថលេខា និង ត្រា

ជា ចាន់តូ

***

ភ្នំពេញ . ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១

## ប្រកាសលេខ ធ ៧.០១ ៤០ ប្រក.

## ស្តីពីការតែងតាំងអភិបាលបណ្តោះអាសន្ន និងអ្នកជំរះបញ្ជី ធនាគារកសិករកម្ពុជា ចំកាត់

≈≈≈

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- បានឃើញអាជ្ញាប័ណ្ណលេខ ០៣ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដែលចេញឱ្យធនាគារកសិកម្មកម្ពុជា ចំកាត់ តទៅនេះហៅថា "ធនាគារ"
- បានឃើញប្រកាសលេខ ធ ៧០០-១១៩ ប្រក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការដកហូតអាជ្ញាប័ណ្ណ និងជំរះបញ្ជីរបស់ធនាគារកសិករកម្ពុជា ចំកាត់

- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

**សម្រេច**

**ប្រការ ១ :**

តែងតាំងលោក Donat Branger ជាអ្នកអភិបាលបណ្ដោះអាសន្ន និងជាអ្នកជំរះបញ្ជី ធនាគារកសិករកម្ពុជា ចំកាត់ ដែលសោហ៊ុយចំណាយជាបន្ទុករបស់ធនាគារកសិករកម្ពុជា ចំកាត់ តាមការកំណត់មាត្រាទី ៥២ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ២ :**

អ្នកជំរះបញ្ជី មានភារកិច្ច :

- រៀបចំជាបន្ទាន់នូវការវាយតំលៃធនាគារ
- ការពារឱ្យបានជាអតិបរមានូវសាធនភាពរបស់ធនាគារ និងរក្សាសិទ្ធិរបស់អ្នកផ្ញើប្រាក់ និងឥណទាយក ។
- ជំរះបញ្ជីទ្រព្យសកម្ម និងសងបំណុលទាំងអស់របស់ធនាគារ ក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។
- មុននឹងបញ្ចប់ការអភិបាលបណ្ដោះអាសន្ន និងការជំរះបញ្ជី ស្នងការគណនីត្រូវធ្វើលិខិតបញ្ជាក់ថា សាមីធនាគារដែលត្រូវត្រួតពិនិត្យបញ្ជីមិនមានការពាក់ព័ន្ធអ្វីទៅអនាគតទេ ប្រសិនបើថ្ងៃក្រោយមានបញ្ហាអ្វីកើតឡើងសាមីធនាគារជាអ្នកទទួលខុសត្រូវដោយខ្លួនឯង ។
- ផ្ដល់ពត៌មានជាទៀងទាត់មកធនាគារជាតិ នៃកម្ពុជា អំពីដំណើការនៃការងារនឹងផ្ញើមកធនាគារជាតិនូវរបាយការណ៍ (ជាភាសាខ្មែរ និងភាសាអង់គ្លេស) អំពីបញ្ហាដែលទាក់ទងទៅនឹងការវិវត្តន៍ការជំរះបញ្ជី ព្រមទាំងបញ្ជាក់ពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារដូចជា :
  - ឥណទានដែលបានផ្ដល់
  - ប្រាក់បញ្ញើរបស់អតិថិជន
  - ចំណាយផ្សេងៗទាក់ទង និងពន្ធដារ

**ប្រការ ៣ :**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៤ :**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសាភិបាល

ហត្ថលេខា និង ត្រា

**ជា ចាន់តូ**

※※※

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាស

ភ្នំពេញ . ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០១

## ប្រកាសលេខ ១២៦ អយក.ប្រក.

## ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ

## នៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ

※※※

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នសរ/កម/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីអំពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១៨៩២ សជណ.អរ. ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការលុបប្រលងសញ្ញាប័ត្រទុតិយភូមិលើកទី ២
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

**ប្រការ ១ :**

មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ត្រូវកំណត់ដោយក្រសួងអប់រំ យុជន និងកីឡា រៀងរាល់ឆ្នាំសិក្សា ។

**ប្រការ ២ :**

ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង និងនាយកគ្រឹះស្ថានសិក្សា ដែលគ្រឹះស្ថានត្រូវបានកំណត់ជាមណ្ឌលប្រលងមានភារៈរៀបចំបន្ទប់ប្រលង និងសំភារៈចាំបាច់សំរាប់ការប្រព្រឹត្តិទៅ នៃការប្រលងឱ្យហើយស្រេច មុនបើកសម័យប្រលង ។

**ប្រការ ៣ :**

មណ្ឌលប្រលងនីមួយៗ ត្រូវមានប្រធាន អនុប្រធាន និងសមាជិកមេប្រយោគមួយចំនួនតាមការចាំបាច់នៃមណ្ឌលប្រលង ។

**ប្រការ ៤ :**

សមាសភាព និងចំនួនព្រមទាំងលិខិតឧទ្ទេសនាមមេប្រយោគ ត្រូវសំរេចដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមសំណើរបស់ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅតាមរយៈអគ្គនាយកអប់រំ ។

**ប្រការ ៥ :**

បន្ទប់ប្រលងនីមួយៗ ត្រូវដាក់បេក្ខជនត្រឹម ២៥ "ម្ភៃប្រាំ" នាក់ ។ បើមានបេក្ខជននៅសល់ ០៥ "ប្រាំ" នាក់ឡើងទៅ ត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក ។

**ប្រការ ៦ :**

ប្រធានមណ្ឌលនៃមណ្ឌលសំនេរនីមួយៗ ជាអ្នកទទួលខុសត្រូវរួម ក្នុងការដំណើការប្រព្រឹត្តិទៅនៃដំណើរការវិញ្ញាសាសរសេរទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេសចំពោះក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៧ :**

ប្រធានមណ្ឌល ត្រូវសហការ ឬធ្វើអន្តរាគមន៍ដល់អាជ្ញាធរមានសមត្ថកិច្ចនានាក្នុងខេត្ត-ក្រុង នៃមណ្ឌលប្រលង ក្នុងករណីចាំបាច់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រលង ។

**ប្រការ ៨ :**

មណ្ឌល ឬ អនុមណ្ឌលប្រលងណាមួយដែលមិនមានភាពប្រក្រតីតាមលក្ខការណ៍ នៃការប្រលង ប្រធានមណ្ឌលនៃមណ្ឌល ឬអនុមណ្ឌលនោះត្រូវរាយការណ៍ជាបន្ទាន់មកគណៈមេប្រយោគទូទាំងប្រទេស និងអាជ្ញាធរដែនដីដើម្បីដោះស្រាយ ឬសុំការសំរេចពីក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៩ :**

ប្រធានមណ្ឌល ត្រូវបែងចែកភារកិច្ចដល់អនុប្រធាន និងសមាជិកមេប្រយោគឱ្យទទួលខុសត្រូវតាមមុខងាររៀងៗខ្លួន ។

**ប្រការ ១០ :**

ភារកិច្ចគណៈកម្មការ អនុគណៈកម្មការ និងសមាជិកមេប្រយោគនឹងមានចែងក្នុងកំរងភារកិច្ចគណៈមេប្រយោគ ។

**ប្រការ ១១ :**

នឹងអនុញ្ញាតឱ្យចុះឈ្មោះប្រលង បានសិស្សថ្នាក់ទី ១២ នៃវិទ្យាល័យសាធារណៈ និងឯកជនដែលបានរៀននៅមធ្យមសិក្សាទុតិយភូមិគ្រប់កំរិតថ្នាក់ បានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី ១២ មានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងគោរពបានត្រឹមត្រូវនូវបទញ្ញត្តិក្នុងសំរាប់គ្រឹះស្ថានមធ្យមសិក្សា ហើយត្រូវបានវាយតំលៃផ្នែកសីលធម៌រស់នៅប្រចាំឆ្នាំ ចាប់ពីមធ្យមឡើងទៅ ។ ពាក្យសុំចុះឈ្មោះប្រលងមានបិទតែម ត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមឋានានុក្រម ។

**ប្រការ ១២ :**

អាចសុំចុះឈ្មោះប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ជាបេក្ខជានស្វ័យរិនបានអតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។

**ប្រការ ១៣ :**

បេក្ខជន ត្រូវភ្ជាប់នឹងពាក្យសុំប្រលងរបស់ខ្លួននូវ :

- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ ១សន្លឹក
- សលាកប័ត្រឯកត្តជនទំហំ ១៥ស.ម គុណនឹង ២១ស.ម មានបិទរូបថតថ្មីថតចំពីមុខ ទំហំ ៤ស.ម គុណនឹង ៦ស.ម ចំនួន ២សន្លឹក ។
- បង្កាន់ដៃបង់សិទ្ធប្រលង ១ច្បាប់ ។
- រូបថត ថតថ្មី ថតចំពីមុខ ទំហំ ៤ស.ម "រូបថតដែលបានបិទលើសលាកប័ត្រឯកត្តជន" ចំនួន ៣សន្លឹក ។
- សៀវភៅសិក្ខាគារិក "ចំពោះសិស្សសាលាឯកជន"

**ប្រការ ១៤ :**

ពាក្យសុំចុះឈ្មោះប្រលង នឹងត្រូវប្រមូលផ្តុំតាមគ្រឹះស្ថានសិក្សា ដែលខ្លួនសិក្សា ។ នាយកគ្រឹះស្ថានសិក្សាត្រូវប្រមូលសំនុំលិខិតរបស់បេក្ខជន បញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដើម្បីធ្វើការបែងចែកនាមត្រកូលបេក្ខជនលំដាប់អក្ខរក្រម (លំដាប់ព្យញ្ជនៈ និងស្រះ) ទៅតាមបន្ទប់ប្រលង ។

**ប្រការ ១៥ :**

បេក្ខជនស្វ័យរិន ត្រូវដាក់ពាក្យសុំប្រលង ដោយមានបញ្ជាក់សម័យប្រលងបណ្ឌលប្រលង លេខបន្ទប់ លេខតុ នៃសម័យប្រលងមុន នៅតាមបន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដែលសាមីខ្លួនបានសុំប្រលងពីមុន ឬនៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ១៦ :**

បន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ត្រូវធ្វើបញ្ជីរាយនាមបេក្ខជន ផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា "នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ" ដើម្បីពិនិត្យ និងសំរេចលើបេក្ខភាព ។

**ប្រការ ១៧ :**

បេក្ខជនត្រូវអនុវត្តតាមបទបញ្ញត្តិទូទៅនៃការប្រលង ដែលមានចែងក្នុងអត្ថបទមួយដោយឡែក ។

**ប្រការ ១៨ :**

វិញ្ញាសា ថេរវេលា និងពិន្ទុនៃការប្រលង សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និងត្រូវបាន កំណត់ដូចតទៅ :

១- តែងសេចក្តី រយៈពេល ២ម៉ោងកន្លះ ត្រូវបានពិន្ទុពី ០ ដល់ ១៥០

២- គណិតវិទ្យា រយៈពេល ២ម៉ោងកន្លះ ត្រូវបានពិន្ទុពី ០ ដល់ ១៥០

៣- វិទ្យាសាស្ត្រពិត រយៈពេល ៣ម៉ោងកន្លះ ត្រូវបានពិន្ទុពី ០ ដល់ ២០០

ក្នុងនោះ :

- រូបវិទ្យា រយៈពេល ១ម៉ោងកន្លះ ត្រូវបានពិន្ទុពី ០ ដល់ ១០០
- គីមី រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ៥០
- ជីវវិទ្យា រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ៥០

៤- វិទ្យាសាស្ត្រសង្គម រយៈពេល ៣ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ១៥០

ក្នុងនោះ :

- ទស្សនវិជ្ជា រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ៥០
- ប្រវត្តិវិទ្យា រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ៥០
- ភូមិវិទ្យា រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ៥០

វិញ្ញាសានីមួយៗនឹងត្រូវបានពិន្ទុសូន្យចំពោះបេក្ខជនអវត្តមាន ឬ បេក្ខជនដែលមិនបាន ប្រគល់សន្លឹកកិច្ចការដល់គណៈមេប្រយោគ ។

**ប្រការ ១៩ :**

ប្រធានវិញ្ញាសាប្រលង ត្រូវយកតាមកម្មវិធីសិក្សាថ្នាក់ទី១២ នៃមធ្យមសិក្សាទុតិយភូមិ ។ វិញ្ញាសាទាំងឡាយជាវិញ្ញាសាសរសេរទាំងអស់ ។

**ប្រការ ២០ :**

ប្រធានវិញ្ញាសាទាំងឡាយត្រូវជ្រើសរើស ឬ តាក់តែងដោយក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ ២១ :**

ប្រធានវិញ្ញាសាទាំងឡាយ ដែលបានជ្រើសរើសរួចហើយ ត្រូវដាក់ក្នុងស្រោមសំងាត់បិទ ជិត និងប្រថាប់ត្រា ហើយត្រូវបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច ដែលមានមណ្ឌលប្រលងតាមរយៈ មេប្រយោគទូទាំងប្រទេសឱ្យថែរក្សាទុកយ៉ាងតិច ៣៦ម៉ោងមុនពេលប្រកាសចាប់ផ្តើមប្រលង ។

**ប្រការ ២២ :**

អាជ្ញាធរមានសមត្ថកិច្ច ដែលថែរក្សាវិញ្ញាសាទាំងនោះ ត្រូវប្រគល់ឱ្យគណៈមេប្រយោគទូទាំងប្រទេសនៅថ្ងៃចាប់ផ្ដើមការប្រលងមួយម៉ោង មុនពេលបើកសម័យប្រលង ។

**ប្រការ ២៣ :**

ការប្រគល់ឱ្យ និងការទទួលយកវិញ នូវប្រធានវិញ្ញាសាប្រឡងត្រូវមានការទទួលខុសត្រូវទាំងសងខាង ដោយការកំណត់ហេតុជាផ្លូវការផង ។

**ប្រការ ២៤ :**

វិញ្ញាសានីមួយៗ ត្រូវមានចំនួនសន្លឹកវិញ្ញាសា ស្មើនឹងចំនួនបេក្ខជន ។ បើខ្វះត្រូវចំលងបន្ថែមបង្គ្រប់ភ្លាម ។

**ប្រការ ២៥ :**

ដំណើរការកំណែត្រូវប្រព្រឹត្តិទៅនៅមណ្ឌលកំណែប្រមូលផ្ដុំនៅរាជធានីភ្នំពេញ ។

**ប្រការ ២៦ :**

មណ្ឌលកំណែត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការកំណែដឹកនាំដោយប្រធានមួយនាក់ ។ ប្រធានមណ្ឌលកំណែជាប្រធាន រឺអនុប្រធានមេប្រយោគទូទាំងប្រទេស ។

**ប្រការ ២៧ :**

បន្ទាប់ពីបញ្ចប់ដំណើរការវិញ្ញាសាសរសេរ មេប្រយោគទូទាំងប្រទេសប្រចាំខេត្ត-ក្រុងនីមួយៗ និងប្រធានមណ្ឌលនៃមណ្ឌលសំណេរនីមួយៗ ត្រូវប្រមូលកិច្ចការបេក្ខជន និងកំណត់ហេតុដំណើរការវិញ្ញាសាសរសេរមកប្រគល់ឱ្យប្រធានមណ្ឌលកំនែ ។

**ប្រការ ២៨ :**

ប្រធាន-អនុប្រធានមណ្ឌលសំណេរនីមួយៗ ត្រូវចូលរួមបន្តការងារនៅមណ្ឌលកំណែ និងអនុវត្តភារកិច្ចតាមការចាត់តាំងរបស់ប្រធានមណ្ឌលកំណែ ។

**ប្រការ ២៩ :**

មណ្ឌលកំណែនីមួយៗត្រូវបែងចែកជាក្រុមមណ្ឌលមុខវិជ្ជា ។

**ប្រការ ៣០ :**

ប្រធាន-អនុប្រធានក្រុមមណ្ឌលមុខវិជ្ជាជ្រើសរើសក្នុងចំណោមគណៈមេប្រយោគទូទាំងប្រទេស ហើយចាំបាច់ត្រូវចុះលេខសំងាត់លើសន្លឹកកិច្ចការបេក្ខជន ។

**ប្រការ ៣១ :**

ពេលចប់កិច្ចការកំណែគ្រប់គណៈកម្មការនានាត្រូវរំសាយ ។ ត្រូវបង្កើតគណៈកម្មការថ្មីមួយសំរាប់ស្រង់បូកពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល ។

**ប្រការ ៣២ :**

ការស្រង់បូកពិន្ទុដោយកុំព្យូទ័រ ប្រព្រឹត្តិទៅនៅការិយាល័យប្រលង នៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

**ប្រការ ៣៣ :**

កិច្ចការបេក្ខជននីមួយៗ ត្រូវកែដោយសមាជិកកំណែទាំងពីរនាក់ជាដាច់ខាត តាមតារាងអត្រាកំណែ ដែលគណៈមេប្រយោគកានតរៀប ។

**ប្រការ ៣៤ :**

ពិន្ទុសរុបនៃពិន្ទុគ្រប់មុខវិជ្ជាហៅថាពិន្ទុប្រលងថ្នាក់ជាតិ ជាពិន្ទុលើ ៦៥០ ។

**ប្រការ ៣៥ :**

ពិន្ទុប្រចាំឆ្នាំស្មើនឹងមធ្យមភាគពិន្ទុឆមាសទី ១ បូកនឹងមធ្យមភាគពិន្ទុឆមាសទី ២ ជាពិន្ទុលើ ១០០ ។

**ប្រការ ៣៦ :**

ពិន្ទុប្រលងស្មើនឹងពិន្ទុប្រចាំឆ្នាំបូកនឹងពិន្ទុប្រលងថ្នាក់ជាតិ ។

**ប្រការ ៣៧ :**

នឹងត្រូវប្រកាសថាប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ បេក្ខជននៃវិទ្យាល័យសាធារណៈ និងឯកជនទាំងឡាយណាដែលបានពិន្ទុប្រលងចាប់ពី ៣៧៥ឡើងទៅ និងបេក្ខជនស្វ័យរិនទាំងឡាយណាដែលបានពិន្ទុប្រលងថ្នាក់ជាតិចាប់ពី ៣២៥ឡើងទៅ ដោយឥតមានពិន្ទុសូន្យចំពោះវិញ្ញាសាណាមួយ ។

ក្នុងករណីចាំបាច់ អាចធ្វើសំរង់អោយជាប់បន្ថែមក្រោយពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡាតាមភាពជាក់ស្តែងនិងតាមសំណើរបស់គណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល ។ បេក្ខជនស្វ័យរិនមិនធ្វើសំរង់ឱ្យជាប់បន្ថែមឡើយ ។

**ប្រការ ៣៨ :**

ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មានភារកិច្ចចុះហត្ថលេខាលើតារាងស្រង់ពិន្ទុ និងបញ្ជីចុះជាប់ធ្លាក់សំរាប់បិទផ្សាយ ។

**ប្រការ ៣៩ :**

និទ្ទេសត្រូវបានកំណត់តាមពិន្ទុប្រលងដូចតទៅ :

- ចំពោះបេក្ខជននៃវិទ្យាល័យសាធារណៈ និងឯកជន :
  - ចាប់ពីពិន្ទុ ៣៧៥ ទៅពិន្ទុ ៤៨៦ និទ្ទេសមធ្យម
  - ចាប់ពីពិន្ទុ ៤៨៧ ទៅពិន្ទុ ៥៩៩ និទ្ទេសល្អបង្គួរ
  - ចាប់ពីពិន្ទុ ៦០០ ឡើងទៅ និទ្ទេសល្អ
- ចំពោះបេក្ខជនស្វ័យរិន :
  - ចាប់ពីពិន្ទុ ៣២៥ ទៅពិន្ទុ ៤២១ និទ្ទេសមធ្យម
  - ចាប់ពីពិន្ទុ ៤២២ ទៅពិន្ទុ ៥១៩ និទ្ទេសល្អបង្គួរ
  - ចាប់ពីពិន្ទុ ៥២០ ឡើងទៅ និទ្ទេសល្អ

**ប្រការ ៤០ :**

បទប្បញ្ញត្តិ ស្តីពីការរៀបចំប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ពីមុនៗទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤១ :**

អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តតាមភារកិច្ចរៀងៗខ្លួន ដើម្បីឱ្យបានសំរេចនូវប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**អ៊ឹម សិទ្ធី**

***

# ២. សារាចរណែនាំ

ភ្នំពេញ . ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០១

## សារាចរណែនាំលេខ ០១ អយក.សរណន.

## ស្តីពីការរៀបចំប្រលងសញ្ញាប័ត្រចំណេះទូទៅ និងបំពេញវិជ្ជា

***

-**យោង** : ប្រកាសលេខ ២១១ អយក.ប្រក. របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី ២៧ មករា ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ។

: ប្រកាសលេខ ១២៦ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី ១៩ កុម្ភៈ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។

-យោងកម្មវិធីការងារប្រលងផ្នែកចំណេះទូទៅ សំរាប់ដំណាច់ឆ្នាំសិក្សា ២០០០-២០០១ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០ ។ ដើម្បីឱ្យការប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ មានលក្ខណៈកាន់តែល្អប្រសើរ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំ ដូចតទៅ :

### I-យន្តការសំរាប់រៀបចំការប្រលង :

#### ១.សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ :

- ខេត្ត-ក្រុង គ្រប់គ្រងផ្ទាល់ការប្រលង តែក្រសួងនឹងចាត់មន្ត្រីពីក្រសួងទៅធ្វើអប្បមាទ ក្នុងមួយមណ្ឌលសំណេរមួយនាក់ ។
- សមាសភាពនៃគណៈកម្មការមេប្រយោគ សុទ្ធតែជាមន្ត្រីអប់រំនៅក្នុងខេត្ត-ក្រុង គ្រាន់តែធ្វើការផ្លាស់ប្តូរមេប្រយោគពីស្រុកមួយទៅស្រុកមួយទៀត ដែលនៅជិតៗគ្នាក្នុងខេត្ត-ក្រុង ។
- មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ធ្វើជាអប្បមាទ តាមគ្រប់មណ្ឌលសំណេររបស់ខេត្ត-ក្រុង ។

- មេប្រយោគទូទាំងប្រទេស មានភារកិច្ចចុះត្រួតពិនិត្យការអនុវត្តន៍ ការងារប្រលងតាមខេត្ត-ក្រុងនីមួយៗ ។

**២.សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ :**

- ក្រសួងគ្រប់គ្រងការប្រលង ។
- សមាសភាពគណៈកម្មការអនុរក្ស និងគណៈកម្មការកណ្តាល ពីជ្រើសរើសមន្ត្រីអប់រំក្នុងខេត្ត-ក្រុង មិនផ្លាស់ប្តូរពីខេត្ត-ក្រុងមួយទៅខេត្ត-ក្រុងមួយទៀតទេ ។
- ប្រធាន-អនុប្រធានមណ្ឌល អប្បមាទ និងគណៈកម្មការត្រួតពិនិត្យតាមអគារ ធ្វើការផ្លាស់ប្តូរពីខេត្ត-ក្រុងមួយទៅខេត្ត-ក្រុងមួយទៀត ។
- គណៈកម្មការកំណែ ជាគ្រូបង្រៀនថ្នាក់ទី ១២ នៃគ្រប់វិទ្យាល័យក្នុងឆ្នាំសិក្សា ២០០០-២០០១ ហើយត្រូវមកបំពេញការងារនៅមណ្ឌលកំណែប្រមូលផ្តុំនៅភ្នំពេញ ។
- ពុំមានបង្កើតគណៈកម្មការស្រង់ បូកពិន្ទុ និងចុះជាប់ធ្លាក់ទេ ។ ក្រសួងនឹងបង្កើតគណៈកម្មការមួយសំរាប់ស្រង់ បូកដោយកុំព្យូទ័រ និងគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល ។
- គណៈកម្មការនានា សំរាប់ដំណើរការប្រលង រៀបចំដូចជាការប្រលងនៅឆ្នាំកន្លងទៅ គ្រាន់តែមុនពេលដំណើរការប្រលងខេត្ត-ក្រុងនីមួយ ត្រូវបង្កើតគណៈកម្មការសំរាប់ធ្វើលិខិតឧទ្ទេសនាម ( តាមគំរូ និងនិយាមដូចមានជូនភ្ជាប់) ។

## II- ដំណើរការប្រព្រឹត្តទៅការប្រលង :

**១.ប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ :**

- ថ្ងៃទី ១ និងទី ២ : ដំណើរការវិញ្ញាសាសរសេរ ។

គណៈកម្មការអនុរក្ស គណៈកម្មការត្រួតពិនិត្យតាមអគារ និងគណៈកម្មការកណ្តាលបំពេញការងារពីរថ្ងៃ ( រួចរំសាយ) ។

- រសៀលថ្ងៃទី ៣ : ប្រជុំគណៈកម្មការក្រុមមណ្ឌលកំណែ ។
- ថ្ងៃទី ៤-៥-៦ : កាត់ក្បាលសន្លឹកកិច្ចការប្រលង និងចុះលេខសំងាត់ ។
- ថ្ងៃទី ៧-៨-៩ : ធ្វើអត្រាកំណែ និងកែកិច្ចការបេក្ខជន ។

គណៈកម្មការកំនែ និងគណៈកម្មការបែងចែកសន្លឹកកិច្ចការបេក្ខជន បំពេញការងារបីថ្ងៃ (រួចរំសាយ) ។

- ថ្ងៃទី ១០-១១ : ស្រង់បូកពិន្ទុ និងចុះជាប់-ធ្លាក់ ។

គណៈកម្មការ ស្រង់បូកពិន្ទុ និងចុះជាប់-ធ្លាប់បំពេញការងារបីថ្ងៃ ។

- ថ្ងៃទី ១២ : ប្រកាសលទ្ធផល ។

**២-ប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ :**

- ថ្ងៃទី១ និងទី២ ( ត្រូវនឹងថ្ងៃទី ២៣-២៤ កក្កដា ២០០១) : ដំណើរការវិញ្ញាសាសរសេរ ។

គណៈកម្មការអនុរក្ស គណៈកម្មការត្រួតពិនិត្យតាមអគារ និងគណៈកម្មការកណ្តាលបំពេញការងារពីរថ្ងៃ (រួចរំសាយ) ។

- ថ្ងៃទី ៤ ពេលព្រឹក : ប្រជុំគណៈកម្មការមណ្ឌលកំណែ ។

ពេលរសៀល : ដឹកវិញ្ញាសាយកទៅកាន់តាមមណ្ឌលកំណែ ។

- ថ្ងៃទី ៥-៦-៧ : កាត់ក្បាលសន្លឹកកិច្ចការប្រលង និងចុះលេខសំងាត់ ។
- ថ្ងៃទី ៨-៩-១០-១១ : ធ្វើអត្រាកំណែ និងកែកិច្ចការបេក្ខជន ។

គណៈកម្មការកំនែ និងបែងចែកសន្លឹកកិច្ចការបំពេញការងារ ៤ថ្ងៃ ។ គ្រប់គណៈកម្មការត្រូវរំសាយ ហើយបង្កើតគណៈកម្មការថ្មីសំរាប់ ស្រង់ពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល ។

- ថ្ងៃទី ១២-២៣ : ស្រង់បូកពិន្ទុ និងចុះជាប់-ធ្លាក់នៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅដោយកុំព្យូទ័រ ។ គណៈកម្មការស្រង់បូកពិន្ទុ និង[illegible]ប់-ធ្លាក់ និងគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល បំពេញការងារ ១៥ថ្ងៃ ។
- ថ្ងៃទី ២៥ ( ត្រូវនឹងថ្ងៃទី ១៥-៨-២០០១) : ប្រកាសលទ្ធផល ។

**III-និយាមប្រើប្រាស់មេប្រយោគ និងចំនួនមេប្រយោគ :**

**III-1-សំរាប់ការប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ :**

| ប្រភេទមេប្រយោគ | មេប្រយោគទូទាំងប្រទេស | មេប្រយោគទូទាំងខេត្ត | ប្រធានអនុប្រធានមណ្ឌល | អប្បមាទ | គណៈកម្មការត្រួតពិនិត្យ | គណៈកម្មការកណ្តាល | គណៈកម្មការអនុរក្ស | គណៈកម្មការបែងចែក | គណៈកម្មការកំណែ | គណៈកម្មការស្រង់បូកពិន្ទុ | គណៈកម្មការប្រចាំមណ្ឌល | គណៈកម្មការរៀបចំការ |
|---|---|---|---|---|---|---|---|---|---|---|---|---|

| | | ក្រុង | | | តាម អគារ | | | សន្លឹក ប្រលង | | និង ចុះជាប់ -ធ្លាក់ | កំនែ | ប្រលង |
|---|---|---|---|---|---|---|---|---|---|---|---|---|
| និយាម | -០១ នាក់ សំរាប់ ខេត្ត-ក្រុង តូច -២ ទៅ ៥ នាក់ សំរាប់ខេត្ត-ក្រុងធំ | ២,៣ នាក់ ក្នុង ១ មណ្ឌល | -ប្រធាន មណ្ឌល នាក់ ក្នុង១ មណ្ឌល អនុប្រធាន មណ្ឌល ១ទៅ៤ នាក់ក្នុង ១ មណ្ឌល | ០,១៥ នាក់ ក្នុង១ បន្ទប់ | ០,៧៥ នាក់ ក្នុង១ បន្ទប់ | ០,៥ នាក់ ក្នុង១ បន្ទប់ | ២,២៥ នាក់ ក្នុង១ បន្ទប់ | ៦៥ នាក់ ក្នុង១ មណ្ឌល | ប្រធាន -អនុ ប្រធាន កំនែ ០,១ នាក់នៃ អ្នកកែ អ្នកកែ -០,៣ នាក់ក្នុង ១បន្ទប់ សំរាប់ គណិត វិទ្យា និង ភាសា ខ្មែរ -០,២ នាក់ក្នុង ១បន្ទប់ សំរាប់ មុខវិជ្ជា ក្រៅពី ភាសា ខ្មែរ និង | ០,៤ នាក់ ក្នុង ១បន្ទប់ | ៤នាក់ ក្នុង មួយ មណ្ឌល កំនែ | ចំនួន ០១ នាក់ ក្នុង បេក្ខ ជន ១៥០០ នាក់ និង ០១ នាក់បើ មាន បេក្ខ ជនពី ០១ នាក់ ដល់ ១៥០០ នាក់ |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | គណិតវិទ្យា ១នាក់ កែ ១២៥ កិច្ចការ សំរាប់ ជីវ កាសា | | | |

III-2-**សំរាប់ការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ** :

| ប្រភេទមេបយោគ | មេប្រយោគទូទាំងប្រទេស | ប្រធានអនុប្រធានមណ្ឌល | អប្បមាទ | គណៈកម្មការត្រួតពិនិត្យតាមអគារ | គណៈកម្មការកណ្ដាល | គណៈកម្មការអនុរក្ស | គណៈកម្មការបែងចែកសន្លឹកកិច្ចការ | គណៈកម្មការកំណែ | ប្រធានកំនែតាមមុខវិជ្ជា | គណៈកម្មការប្រចាំមណ្ឌលកំនែ | គណៈកម្មការរៀបចំការប្រលង |
|---|---|---|---|---|---|---|---|---|---|---|---|
| និយាម | ២នាក់សំរាប់ខេត្ត-ក្រុងតូច និង៣ទៅ៥នាក់សំរាប់ខេត្ត-ក្រុងធំ | -ប្រធានមណ្ឌល ១នាក់ក្នុង១មណ្ឌល -អនុប្រធាន ១ទៅ៤នាក់ក្នុង ១ មណ្ឌល | ០,១៥ នាក់ក្នុង១បន្ទប់ | ០,៧៥ នាក់ក្នុង១បន្ទប់ | ០,៥ នាក់ក្នុង១បន្ទប់ | ២,២៥ នាក់ក្នុង១បន្ទប់ | ៦៥ នាក់ក្នុង១មណ្ឌល | - ០,៣នាក់ក្នុង១បន្ទប់សំរាប់ភាសាខ្មែរ និងគណិតវិទ្យា ០,២នាក់ក្នុង១បន្ទប់ | -០,១៥ នាក់នៃអ្នកកែតាមមុខវិជ្ជា | ៤នាក់ក្នុង មួយមណ្ឌលកំនែ | ចំនួន ០១នាក់ក្នុងបេក្ខជន២០០០នាក់ និង ០១នាក់បើមានបេក្ខជ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សំរាប់ មុខវិជ្ជា ដទៃ ទៀត | | | នពី ០១នា ក់ដល់ ២០០០ នាក់ |

ការគិតចំនួនមេប្រយោគ តាមនិយាមដូចមានក្នុងតារាង នឹងមានពន្យល់លំអិតភ្ជាប់ជាមួយគំរូលិខិតឧទ្ទេសនាម គណៈកម្មការនីមួយៗនៃមេប្រយោគប្រលង សំរាប់ឱ្យខេត្ត-ក្រុងផ្តល់ចំនួនពិតប្រាកដមកនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

IV-**ការរៀបចំលិខិតឧទ្ទេសនាម :**

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ត្រូវរៀបចំគណៈកម្មការមួយ សំរាប់ធ្វើពង្រាងលិខិតឧទ្ទេសនាមមេប្រយោគប្រលង និងបញ្ជីផ្សេងៗ តាមការណែនាំដូចតទៅ :

**១-ប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ :**

*១-ពង្រាងលិខិតឧទ្ទេសនាម គណៈមេប្រយោគទូទាំងខេត្ត-ក្រុង* ( គំរូទី១ជូនភ្ជាប់ )

- សមាសភាព គណៈមេប្រយោគទូទាំងខេត្ត-ក្រុង រួមមាន :
- ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ------------------------------ ប្រធាន
- អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា------------------------------ អនុប្រធាន
- ប្រធាន រឺអនុប្រធានការិ.មធ្យមសិក្សា ការិ.ប្រលង ការិ.អប់រំក្រៅប្រព័ន្ធ ការិ.ផែនការ និងគណនេយ្យនៃមន្ទីរអប់រំនៃមន្ទីរអប់រំ យុវជន និងកីឡា--------------- សមាជិក
- ប្រធាន រឺអនុប្រធានការិ.អប់រំ យុវជន និងកីឡា ខ័ណ្ឌ-ស្រុក ដែលមានមណ្ឌលប្រលង ------------------------------------------ សមាជិក

*២-ពង្រាងលិខិតឧទ្ទេសនាម មេប្រយោគសំរាប់ដំណើរការវិញ្ញាសាសរសេរ* ( គំរូទី២ជូនភ្ជាប់ )

២.១. សមាសភាពប្រធាន-អនុប្រធានមណ្ឌលប្រលង ជ្រើសរើសក្នុងចំណោមនាយក-នាយករងវិទ្យាល័យ អនុវិទ្យាល័យ ដែលមានលក្ខណៈសម្បត្តិល្អ និងឈ្លាសវៃ ។

- សមាសភាពគណៈកម្មការកណ្តាល ជ្រើសរើសក្នុងចំណោម បុគ្គលិកការិយាល័យនៃវិទ្យាល័យ អនុវិទ្យាល័យ និងបុគ្គលិកនៃមន្ទីរអប់រំ យុវជន និងកីឡា ដែលមានគុណសម្បត្តិល្អ និងមានសមត្ថភាពផ្នែករដ្ឋបាល ។

- សមាសភាពគណៈកម្មការអនុរក្ស ជ្រើសរើសក្នុងចំណោមលោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី ៧ និងទី ៨ ។
- សមាសភាពគណៈកម្មការត្រួតពិនិត្យតាមអគារជ្រើសរើសក្នុងចំណោម នាយករងវិទ្យាល័យ បុគ្គលិកការិយាល័យនៃមន្ទីរអប់រំ យុវជន និងកីឡា ។ បុគ្គលិកការិយាល័យនៃវិទ្យាល័យ អនុវិទ្យាល័យ និងលោកគ្រូ អ្នកគ្រូ បង្រៀនថ្នាក់ទី ៧ និងទី ៨ ដែលសកម្ម ឈ្លាសវៃ ម៉ត់ចត់នឹងការងារ ។ *(គំរូ២.១ជូនភ្ជាប់)*

២.២. សមាសភាពគណៈកម្មការអប្បមាទ ជ្រើសរើសក្នុងចំណោម នាយក-នាយករងវិទ្យាល័យ-អនុវិទ្យាល័យ និងប្រធាន-អនុប្រធានការិយាល័យនៃមន្ទីរអប់រំ យុវជន និងកីឡា ដែលមានបទពិសោធ ស្ទាត់ដៃ និងឈ្លាសវៃ ។ *(គំរូ២.២ជូនភ្ជាប់)*

*៣-ពង្រាងលិខិតឧទ្ទេសនាម អ្នកកែតាមមុខវិជ្ជា* ( គំរូទី៣ជូនភ្ជាប់ )

- សមាសភាពអ្នកកែតាមមុខវិជ្ជានីមួយៗ គឺជ្រើសរើសក្នុងចំណោមលោកគ្រូ អ្នកគ្រូ ដែលបង្រៀនថ្នាក់ទី ៩ ។ ក្នុងនោះមាន :
- ប្រធាន អនុប្រធានបច្ចេកទេសតាមមុខវិជ្ជាមួយចំនួន ---------------- ប្រធាន
- ប្រធាន អនុប្រធានបច្ចេកទេសតាមមុខវិជ្ជាមួយចំនួន ---------------- អនុប្រធាន
- លោកគ្រូ អ្នកគ្រូតាមមុខវិជ្ជា --------------------------------- សមាជិក

*៤-ពង្រាងលិខិតឧទ្ទេសនាម គណៈកម្មការគ្រប់គ្រង និងបែងចែកសន្លឹកកិច្ចការប្រលង និងគណៈកម្មការស្រង់បូកពិន្ទុ និងចុះដាប់-ធ្លាក់* ( គំរូទី៤ជូនភ្ជាប់ )

សមាសភាពគណៈកម្មការទាំងនេះ ជ្រើសរើសក្នុងចំណោម បុគ្គលិកការិយាល័យនៃវិទ្យាល័យ អនុវិទ្យាល័យ និងបុគ្គលិកការិយាល័យនៃមន្ទីរអប់រំ យុវជន និងកីឡា ដែលមានគុណសម្បត្តិល្អ ។

- ចំពោះខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង កោះកុង ក្រុងកែប ក្រុងប៉ៃលិន ឧត្តរមានជ័យ និងខេត្តដែលមានមួយក្រុមមណ្ឌលកំណែ មិនបាច់រៀបចំគណៈកម្មការនេះទេ ។

## ២. ប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ :

*១-ពង្រាងលិខិតឧទ្ទេសនាម សំរាប់ដំណើការវិញ្ញាសាសរសេរ* ( គំរូទី៦ ជូនភ្ជាប់ )

- មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង គ្រាន់តែរៀបចំសមាសភាពគណៈកម្មការ កណ្តាល និងគណៈកម្មការអនុរក្សតែប៉ុណ្ណោះ ។
  - សមាសភាពគណៈកម្មការកណ្តាល ជ្រើសរើសចំរុះក្នុងចំណោម បុគ្គលិកការិយាល័យនៃគ្រប់វិទ្យាល័យក្នុងខេត្ត-ក្រុង ។
  - សមាសភាពអនុរក្ស ជ្រើសរើសចំរុះក្នុងចំណោមលោកគ្រូ អ្នកគ្រូដែលបង្រៀនថ្នាក់ទី ១០ និងថ្នាក់ទី ១១ នៃគ្រប់វិទ្យាល័យក្នុងខេត្ត-ក្រុង ។ ចំពោះខេត្ត-ក្រុងធំ ដែលមានមណ្ឌលប្រលងច្រើន ត្រូវរៀបចំអនុរក្សយ៉ាងណាកុំឱ្យគ្រូ និងសិស្សមានអគតដ្ឋានដូចគ្នា ។

*២-ចំពោះការរៀបចំគណៈកម្មការអនុប្រយោគផ្សេងៗទៀត ក្រសួងអប់រំ យុវជន និងកីឡា ជាអ្នករៀបចំ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង គ្រាន់តែរៀបចំបន្ថែមនូវ :*

២.១. បញ្ជីរាយនាមប្រធាន-អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ប្រធាន-អនុប្រធានការិ. មធ្យមសិក្សា ការិ.ប្រលង ការិ.អប់រំក្រៅប្រព័ន្ធ ។ *(គំរូទី៧ ជូនភ្ជាប់)*

២.២. សំណើប្រធាន អនុប្រធានមណ្ឌល នឹងត្រូវគិតតាមនិយាមដែលបានកំនត់ ដោយគិតសមាមាត្រនឹងចំនួនបន្ទប់ប្រលងសរុបដែលមាននៅក្នុងខេត្ត-ក្រុងរបស់ខ្លួន។ *(គំរូទី៨ ជូនភ្ជាប់)*

ប្រធាន-អនុប្រធានមណ្ឌលជ្រើសរើសក្នុងចំណោមនាយក នាយករងវិទ្យាល័យ ។

២.៣. សំណើអប្បមាទត្រូវគិតតាមនិយាម ០,០៥ ដោយគិតធៀបនឹងចំនួនបន្ទប់សរុបក្នុងខេត្ត-ក្រុង ។

អប្បមាទជ្រើសរើសក្នុងចំណោម នាយក នាយករងវិទ្យាល័យ ប្រធាន អនុប្រធានការិ. មធ្យមសិក្សា ការិយាល័យប្រលង និងការិ.អប់រំក្រៅប្រព័ន្ធ ។ *(គំរូទី៩ ជូនភ្ជាប់)*

២.៤. បញ្ជីរាយនាម និងសលាកប័ត្រពតិមានរបស់គ្រូបង្រៀនថ្នាក់ទី ១២ តាមមុខវិជ្ជា ។ *(គំរូទី១០ និងទី១១ ជូនភ្ជាប់)*

២.៥. បញ្ជីរាយនាមអ្នកត្រួតពិនិត្យតាមអគារ ។ អ្នកត្រួតពិនិត្យតាមអគារ ជ្រើសរើសក្នុងចំណោមបុគ្គលិកការិយាល័យនៃមន្ទីរអប់រំ យុវជន និងកីឡា នាយករងវិទ្យាល័យ នាយក នាយករងអនុវិទ្យាល័យដែលឈ្លាសវៃ និងម៉ត់ចត់ក្នុងការងារតាមនិយាម ០,៥៥ ក្នុងមួយបន្ទប់ ។ *(គំរូទី១២ ជូនភ្ជាប់)*

V-**ការផ្ញើសំនុំលិខិត** :

មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ត្រូវផ្ញើទៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ឱ្យបានមុនថ្ងៃ ១០ មិថុនា ២០០១ នូវ :

១- ពង្រាងលិខិតឧទ្ទេសនាមគណៈមេប្រយោគទូទាំងខេត្ត (សមបភ) ។ (*គំរូទី១*)

២- ពង្រងលិខិតឧទ្ទេសនាមមេប្រយោគសំរាប់ដំណើរការវិញ្ញាសាសរសេរ (សមបភ) ។ (*គំរូទី២-១*)

៣- ពង្រាងលិខិតឧទ្ទេសនាមអប្បមាទ (សមបភ) ។ (*គំរូទី២-២*)

៤- ពង្រាងលិខិតឧទ្ទេសនាមអ្នកកែតាមមុខវិជ្ជា (សមបភ) ។ (*គំរូទី៣*)

៥- ពង្រាងលិខិតឧទ្ទេសនាមគណៈកម្មការគ្រប់គ្រង និងបែងចែកសន្លឹកកិច្ចការប្រលង ផងគណៈកម្មការ ស្រង់បូកពិន្ទុ និងចុះជាប់-ធ្លាក់ (សមបភ) ។ (*គំរូទី៤*)

៦- សំណើប្រធាន អនុប្រធានមណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ។ (*គំរូទី៥ជូនភ្ជាប់*)

៧- ពង្រាងលិខិតឧទ្ទេសនាមសំរាប់ដំណើរការវិញ្ញាសាសរសេរ (សមទភ) ។ (*គំរូទី៦*)

៨- បញ្ជីរាយនាមប្រធាន-អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ប្រធាន-អនុប្រធាន ការិ. មធ្យមសិក្សាការិ. ប្រលង ការិ.អប់រំក្រៅប្រព័ន្ធ នៃមន្ទីរអប់រំ យុវជន និងកីឡា (សមទប) ។ (*គំរូទី៧*)

៩- សំណើប្រធាន អនុប្រធានមណ្ឌល និងអប្បមាទ (សមទភ) ។ (*គំរូទី៨*)

១០- សំណើអប្បមាទពីមន្ទីរអយក. ខេត្ត-ក្រុង ។ (*គំរូទី៩*)

១១- បញ្ជីរាយនាម និងសលាកប័ត្រពត៌មានរបស់គ្រូបង្រៀនថ្នាក់ទី ១២ តាមមុខវិជ្ជា (សមទភ) ។ (*គំរូទី១០ និង១១*)

១២- សំណើអ្នកត្រួតពិនិត្យតាមអគារ ។ (*គំរូទី១២*)

១៣- ស្ថិតិវិទ្យាល័យ អនុវិទ្យាល័យ (សមទភ) ។ (*គំរូទី១៣*)

១៤- បញ្ជីរាយនាមនាយកវិទ្យាល័យ ។ (*គំរូទី១៤*)

១៥- បញ្ជីរាយនាមនាយករងវិទ្យាល័យ ។ (*គំរូទី១៥*)

១៦- បញ្ជីរាយនាមនាយកអនុវិទ្យាល័យ ។ (*គំរូទី១៦*)

១៧- បញ្ជីរាយនាមនាយករងអនុវិទ្យាល័យ ។ ( *គំរូទី១៧* )

១៨- លិខិតឧទ្ទេសនាមគណៈកម្មការ រៀបចំការប្រលង ។ ( *គំរូទី១៨ជូនភ្ជាប់* )

**កំណត់សំគាល់ :**

វិទ្យាល័យអនុវត្ត ត្រូវបញ្ជូនបញ្ជីឈ្មោះ នាយក នាយករង បុគ្គលិកបង្រៀន និងបុគ្គលិកការិយាល័យ និងពាក្យសុំប្រលងរបស់បេក្ខជនទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ។

ក្រសួងសង្ឃឹមថា លោក-លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡាគ្រប់ខេត្ត-ក្រុង និងខិតខំអនុវត្តការណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**អ៊ឹម សិទ្ធី**

***

ភ្នំពេញ . ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០១

**សារាចរណែនាំលេខ ០២ អយក.សរណន.**

**ស្តីពី**

**ការប្រលងបញ្ចប់ភូមិសិក្សាផ្នែកចំណេះទូទៅ**

**បំពេញវិជ្ជាសាធារណៈ និងឯកជន**

***

**យោង** : ប្រកាសលេខ ២១១ អយក.ប្រក. របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី ២៧ មករា ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការប្រលងសញ្ញាប័ត្រ មធ្យមសិក្សាបឋមភូមិ

: ប្រកាសលេខ ១២៦ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី ១៩ កុម្ភៈ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការប្រលងសញ្ញាប័ត្រមធ្យម សិក្សាទុតិយភូមិ ។

: សេចក្តីណែនាំលេខ ៣៨៨១ អយក.ចទម. ចុះថ្ងៃទី ១៤ ធ្នូ ២០០០ ស្តីពីការរៀបចំប្រលងឆមាសនៅគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសំរាប់ឆ្នាំ ២០០០-២០០១ ។

នៅឆ្នាំសិក្សា ២០០០-២០០១ នេះ ពិន្ទុសរុបនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សា បឋមភូមិ និងទុតិយភូមិ នៅរក្សាយកពិន្ទុប្រចាំឆ្នាំ បូកនឹងពិន្ទុប្រលងថ្នាក់ជាតិ ។

ដើម្បីឱ្យការរៀបចំប្រលងថ្នាក់ជាតិ និងការរៀបចំប្រលងតាមសាលារៀន មានលក្ខណៈល្អប្រសើរ ក្រសួងសូមធ្វើការណែនាំដូចតទៅ ៖

I-កាលបរិច្ឆេទប្រលង ៖

I.1. ប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ៖

- កាលបរិច្ឆេទ ៖ ថ្ងៃទី ២៣ កក្កដា ២០០១ ។
- កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រលង ៖ ថ្ងៃទី ០១ មីនា ២០០១ ដល់ថ្ងៃទី ៣០ មីនា ២០០១ ។

I.2. ប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ៖

- កាលបរិច្ឆេទ ៖ ថ្ងៃទី ១៣ សីហា ២០០១ ។
- កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រលង ៖ ថ្ងៃទី ០១ មីនា ២០០១ ដល់ថ្ងៃទី ៣០ មីនា ២០០១ ។

II-បេក្ខភាពសិស្ស និងសំណុំលិខិតដាក់ពាក្យសុំប្រលង ៖

II.1. សំនុំលិខិតដាក់ពាក្យសុំប្រលងរបស់បេក្ខជន ត្រូវសរសេរដោយដៃបេក្ខជនផ្ទាល់(ត្រូវជូនភ្ជាប់)រូបថតមួយ ៣០០រៀល និងមានភ្ជាប់បង្កាន់ដៃបង់សិទ្ធិប្រលងដូចខាងក្រោម ៖

- បេក្ខជនប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ បង់ថ្លៃសិទ្ធប្រលង ១០០០រៀល
- បេក្ខជនប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ បង់ថ្លៃសិទ្ធប្រលង ១៥០០រៀល ។

II.2. បេក្ខភាព ៖

- សិស្សសាលារៀនចំណេះទូទៅសាធារណៈ និងឯកជន ៖
  - ដែលមានអាយុ ១៤ឆ្នាំ យ៉ាងតិច
  - បានរៀនចប់នៅមធ្យមសិក្សាបឋមភូមិ គ្រប់ការិតថ្នាក់
  - បានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី ៩
  - បានគោរពត្រឹមត្រូវនូវបទបញ្ជាផ្ទៃក្នុង សំរាប់គ្រឹះស្ថានមធ្យមសិក្សា
  - បានត្រូវវាយតំលៃផ្នែកសីលធម៌ប្រចាំឆ្នាំ ចាប់ពីមធ្យមឡើងទៅ អាចដាក់ពាក្យសុំប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនបាន ។
- សិស្សសាលារៀនចំណេះទូទៅសាធារណៈ និងឯកជន ៖
  - ដែលមានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ
  - បានរៀននៅមធ្យមសិក្សាទុតិយភូមិគ្រប់ការិតថ្នាក់

- បានរៀនចប់កម្មវិធីថ្នាក់ទី ១២
- បានគោរពត្រឹមត្រូវនូវបទបញ្ជាផ្ទៃក្នុង សំរាប់គ្រឹះស្ថានមធ្យមសិក្សា
- បានត្រូវវាយតំលៃផ្នែកសីលធម៌ប្រចាំឆ្នាំ ចាប់ពីមធ្យមឡើងទៅ អាចដាក់ពាក្យសុំប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនបាន ។

*លើកលែងតែ* :

- សិស្សដែលឈប់ដោយមានច្បាប់ ចាប់ពី ៤៥ដង ឡើងទៅ ។
- សិស្សដែលឈប់ឥតច្បាប់ និងមានច្បាប់ ចាប់ពី ៣០ដង ឡើងទៅ ។
- សិស្សដែលឈប់ឥតច្បាប់ ចាប់ពី ២០ដង ឡើងទៅ ។
- សិស្សដែលគ្មានមធ្យមភាគពិន្ទុឆមាសទី ១ រឺឆមាសទី ២ ។

- អតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ អាចដាក់ពាក្យសុំប្រលងសញ្ញាប័ត្រ មធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដែលសាមីខ្លួន បានសុំប្រលងពីមុន រឺអាចដាក់ពាក្យសុំប្រលងនៅតាមមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុងផ្សេងទៀត ដោយគ្រាន់តែធ្វើសេចក្តីបញ្ជាក់ពីការប្រលងធ្លាក់លើពាក្យសុំប្រលងពី មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ដែលសាមីខ្លួនបានប្រលងធ្លាក់ពីមុន ។
- អតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ អាចដាក់ពាក្យសុំប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ដែលសាមីខ្លួនបានសុំប្រលងពីមុន រឺនៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា ។

**កំណត់សំគាល់ :**

- ចំនួនអវត្តមានត្រូវគិតចាប់ពីបើកបវេសនកាល រហូតដល់ថ្ងៃទី ១៥ មិថុនា ២០០១ សំរាប់សិស្សថ្នាក់ទី ១២ និងថ្ងៃទី ៣០ មិថុនា ២០០១ សំរាប់សិស្សថ្នាក់ទី ៩
- លោកនាយកសាលា :
  - ត្រូវពិនិត្យសំនុំលិខិតដាក់ពាក្យសុំប្រលងរបស់សិស្ស ដោយផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវនូវឈ្មោះ ថ្ងៃ.........ខែ..........ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុក ម្តាយរបស់សិស្ស

ដែលសរសេរក្នុងពាក្យសុំប្រលង និង សលាកប័ត្រឯកត្តជននិងអត្តសញ្ញាណប័ណ្ណ ។ ពាក្យសុំប្រលង និងសលាកប័ត្រឯកត្តជនរបស់សិស្ស ត្រូវសរសេរឱ្យច្បាស់ ។

- ត្រូវណែនាំឱ្យសិស្សសរសេរសំនុំលិខិតដាក់ពាក្យសុំប្រលងដោយខ្លួនឯង ចៀសវាងប្រមូលយកទៅឱ្យគ្រូទទួលបន្ទុកថ្នាក់ មិត្តភក្តិ រឺអ្នកដទៃសរសេរជំនួស ។
- ត្រូវចុះហត្ថលេខា និងបោះត្រាលើសលាកប័ត្រពិន្ទុប្រចាំឆ្នាំ របស់សិស្សថ្នាក់ទី ៩ (បេក្ខជនម្នាក់បំពេញ ២ ច្បាប់) ដែលសរសេរបំពេញដោយផ្ទាល់ដៃសិស្ស ចៀសវាងការកោសលុប រឺសរសេរត្រួត ។ ចំពោះសិស្សថ្នាក់ទី ១២ ពុំមានសលាកប័ត្រពិន្ទុប្រចាំឆ្នាំទេ ។

បន្ទាប់ពីឈប់ទទួលពាក្យសុំប្រលង ត្រូវរាប់ចំនួនសិស្សដាក់ពាក្យសុំប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងចំនួនសិស្សដាក់ពាក្យសុំប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ផ្ញើមកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដោយ :

- រៀបបញ្ជីសិស្សថ្នាក់ទី ១២ តាមអក្ខរក្រមជា ២ច្បាប់ ផ្ញើមកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងឱ្យបានមុនថ្ងៃទី ៣០ មករា ២០០១ គឺ បញ្ជី :
  - ១ច្បាប់ សំរាប់មន្ទីរអប់រំ យុវជន និងកីឡា ដើម្បីវាយឈ្មោះសិស្សបញ្ចូល Diskette តាមវិទ្យាល័យនីមួយៗ រួចមន្ទីរផ្ញើ Diskette នោះមកនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅឱ្យបានមុនថ្ងៃទី ៣០ មេសា ២០០១ ។
  - ១ច្បាប់ សំរាប់ក្រសួង (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ) ដោយភ្ជាប់វិញ្ញាបនប័ត្របណ្តោះអាសន្នបឋមភូមិសម័យប្រលងត្រឹមឆ្នាំ ១៩៩៨ រឺមុនឆ្នាំ ១៩៩៨ ឱ្យបានមុនថ្ងៃទី ២០ កុម្ភៈ ២០០១ ដើម្បីក្រសួងផ្ទៀងផ្ទាត់បេក្ខភាព ។

## III-**ការកំណត់មណ្ឌលប្រលង** :

កន្លងមក គ្រឹះស្ថានសិក្សាមួយចំនួននៅតាមខេត្ត-ក្រុង ដែលត្រូវបានយកធ្វើជាមណ្ឌលប្រលង នាយកសាលាពុំទាន់បានខិតខំរៀបចំឱ្យអស់ពីលទ្ធភាព ដើម្បីធានាឱ្យដំណើរការប្រលងប្រព្រឹត្តទៅបានល្អប្រសើរនៅឡើយ ។

ដូចនេះ លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ត្រូវជ្រើសរើសយកគ្រឹះស្ថានណា ដែលមានដំបូលពុំធ្លុះធ្លាយមានរបងព័ទ្ធជុំវិញ មានមាត់ច្រកចេញ-ចូល មានសោរចាក់ត្រឹមត្រូវសំរាប់ធ្វើ

ជាមណ្ឌលប្រលង និងណែនាំឱ្យនាយកសាលាដែលសាលារបស់ខ្លួនត្រូវបានជ្រើសរើសធ្វើជាមណ្ឌលប្រលង សំអាតទីធ្លា អគារ បន្ទប់អនាម័យ ឱ្យហើយស្រេចមុនដំណើការប្រលង ។ បន្ទប់ប្រលងនីមួយៗ ត្រូវរៀបចំឱ្យមានតុ ជើងម៉ាមាំទាំ ដើម្បីឱ្យបេក្ខជនងាយស្រួលក្នុងការសរសេរកិច្ចការ ។ បើតុជើងម៉ាពុំមាំទាំ ត្រូវជួសជុល រឺរកជើងម៉ាថ្មីមកប្តូរ ។ បន្ទប់ប្រលងនីមួយៗ ត្រូវឱ្យមានតុ ២៥យ៉ាងតិច (តុសំរាប់សិស្សអង្គុយរៀនធម្មតាពីរនាក់) និង ១៣តុយ៉ាងតិច (តុសំរាប់សិស្សអង្គុយរៀនធម្មតាបួននាក់) ។

មណ្ឌលប្រលងនីមួយៗ ត្រូវមានប្រដាប់បំពងសំលេង ដែលអាចប្រើប្រាស់បាននៅពេលដំណើរការប្រលង ។ បុគ្គលិក ២នាក់ ត្រូវរក្សាទុកសំរាប់ប្រចាំសាលា ដែលត្រូវយកធ្វើជាមណ្ឌលប្រលង ត្រូវជ្រើសរើសអ្នកដែលចេះប្រើប្រាស់ និងរៀបចំប្រដាប់បំពងសំលេង ហើយឈ្លាសវៃក្នុងការដោះស្រាយកង្វះខាតសំភារៈផ្សេងៗ ។ ហាមដាច់ខាត ការលក់ដូរនៅក្នុងមណ្ឌលប្រលង ក្នុងរយៈពេលដំណើរការការងារប្រលង ។ ត្រូវផ្ញើគំរោងតមណ្ឌលប្រលងទៅក្រសួង (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ) ឱ្យបានមុនថ្ងៃទី ១៥ ឧសភា ២០០១ ។

## IV-សំណើប្រធានវិញ្ញាសាប្រលង :

លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី ១២ និងទី ៩ ត្រូវផ្ញើសំណើប្រធានវិញ្ញាសាមុខវិជ្ជាប្រលង ១វិញ្ញាសាមួយមុខវិជ្ជាសំរាប់អ្នកបង្រៀនម្នាក់ ដោយភ្ជាប់អត្រាកំនែមកជាមួយផង ដើម្បីជាទុកសំរាប់ក្រសួងពិចារណា និងជ្រើសរើស ។ លោកគ្រូ អ្នកគ្រូដែលជាអ្នកស្នើប្រធានវិញ្ញាសា ត្រូវរក្សាការសំងាត់ និងតំលៃមុខវិជ្ជារបស់ខ្លួន ដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះមុខក្រសួង ។

ផ្នែកខាងលើនៃសំនើប្រធានវិញ្ញាសានិមួយៗ ត្រូវសរសេរតាមគំរូជូនភ្ជាប់ ។ សំណើប្រធានវិញ្ញាសានីមួយៗត្រូវដាក់ក្នុងស្រោមសំងាត់ ដោយបញ្ជាក់មុខវិជ្ជាលើស្រោមនោះផង ។

នាយកសាលា ត្រូវប្រមូលស្រោមសំណើប្រធានវិញ្ញាសាទាំងអស់ ដាក់ក្នុងស្រោមសំងាត់រួម រួចផ្ញើទៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ឱ្យបានមុនថ្ងៃទី ១៥ មិថុនា ២០០១ ។

ចំពោះវិញ្ញាសាដែលត្រូវធ្វើសំណើមានដូចតទៅ :

### ក-សំរាប់ការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ :

១- តែងសេចក្តី ------------ រយៈពេល ២ម៉ោង ៣០នាទី ត្រូវបានពិន្ទុពី ០ ដល់ ១៥០ ។

២- គណិតវិទ្យា ---------------- រយៈពេល ២ម៉ោង ៣០នាទី ត្រូវបានពិន្ទុពី ០ ដល់ ១៥០ ។

៣- រូបវិទ្យា ---------------- រយៈពេល ១ម៉ោង ៣០នាទី ត្រូវបានពិន្ទុពី ០ ដល់ ១០០ ។

៤- គីមី ------------------ រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ៥០ ។

៥- ជីវវិទ្យា ---------------- រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ៥០ ។

៦- ទស្សនវិជ្ជា-------------- រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ៥០ ។

៧- ប្រវត្តិវិទ្យា -------------- រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ៥០ ។

៨- ភូមិវិទ្យា--------------- រយៈពេល ១ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ៥០ ។

**ខ_សំរាប់ការប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ :**

១- តែងសេចក្តី ------------- រយៈពេល ២ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ១០០ ។

២- គណិតវិទ្យា ------------- រយៈពេល ២ម៉ោង ត្រូវបានពិន្ទុពី ០ ដល់ ១០០ ។

៣- រូបវិទ្យា --------------- រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣០ ។

៤- គីមី ----------------- រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ២៨ ។

៥- ជីវវិទ្យា --------------- រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ២៨ ។

៦- សីលធម៌-ពលរដ្ឋវិជ្ជា------ រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ៣០ ។

៧- ប្រវត្តិវិទ្យា ------------- រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ២៨ ។

៨- ភូមិវិទ្យា--------------- រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ២៨ ។

៩- ផែនដីវិទ្យា ------------- រយៈពេល ៤០នាទី ត្រូវបានពិន្ទុពី ០ ដល់ ២៨ ។

១០- ភាសាបរទេស ----------- រយៈពេល ៤៥នាទី ត្រូវបានពិន្ទុពី ០ ដល់ ៥០ ។

លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ត្រូវផ្សព្វផ្សាយការណែនាំនេះ ដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សា ដើម្បីឱ្យការអនុវត្តន៍មានប្រសិទ្ធភាព ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**អ៊ឹម សិទ្ធី**

***

## ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០១

### ប្រកាសលេខ ០៨៤ ប្រក.កសក.ប្រ

### ស្តីពីការបង្កើតការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ

-----

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ ១៤៧០ ប្រក.កសក ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានជលផល
- តាមសំណើរបស់ប្រធាននាយកដ្ឋានជលផល

### សំរេច

**ប្រការ ១ :**

បង្កើតការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ២ :**

ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ មានភារកិច្ចដូចតទៅ :

- ជាសេនាធិការឱ្យនាយកដ្ឋាន ជលផល លើការងារស្រាវជ្រាវផ្នែកសេដ្ឋកិច្ចសង្គម និងអភិវឌ្ឍន៍សហគមន៍នេសាទ ។
- រៀបចំប្រព័ន្ធការងារស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ចសង្គម និងវិភាគសេដ្ឋកិច្ចជលផល ។
- រៀបចំការអភិរក្ស ធនធានជលផលជាមួយសហគមន៍នេសាទ ។
- ចងក្រងលក្ខន្តិកៈដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍នេសាទ ។
- សហការជំរុញការងារអភិវឌ្ឍន៍សហគមន៍នេសាទ ។
- ទំនាក់ទំនងជាមួយបណ្តាសមាគម អង្គការជាតិ អង្គការអន្តរជាតិនានា និងស្ថាប័នពាក់ព័ន្ធដើម្បីជំរុញ និងលើកកំពស់កិច្ចអភិវឌ្ឍន៍សហគមន៍នេសាទ ។

**ប្រការ ៣ :**

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅរបស់ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ អាស្រ័យដោយប្រធាននាយកដ្ឋានជលផល កំណត់សំរេច ។

**ប្រការ ៤ :**

ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការ ។

**ប្រការ ៥ :**

អគ្គនាយកក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋាន ផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានជលផល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និង ត្រា

**ច័ន្ទ តុងអ៊ីវ**

***